# ទស្សនាវដ្ដី បរិស្ថាន



លេខ ១១ ខែ មេសា ឆ្នាំ ២០០៤

# អារម្ភកថា

**ឈាន**ចូលឆ្នាំ២០០៤នេះ ក្រសួងបរិស្ថានមានអតីតភាពរបស់ខ្លួន១១ឆ្នាំហើយក្នុងការបំពេញបេសកកម្មជាប្រវត្តិសាស្ត្រជាមួយនឹងស្ថាប័នពាក់ព័ន្ធក្នុងកិច្ចគាំពារ ការពារ និង អភិរក្ស ធនធានធម្មជាតិ ដើម្បីរក្សាលំនឹងបរិស្ថានបានល្អប្រសើរ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលដែលមានសម្តេច **ហ៊ុន សែន** ជាប្រមុខ។ ទោះបីបញ្ហាបរិស្ថានសព្វថ្ងៃនៅមានលេចឡើងរូបភាពអសកម្មខ្លះដែលមិនទាន់ធានាសន្តិសុខបរិស្ថានបាន១០០%យ៉ាងណាក៏ដោយ តែលទ្ធផលដែលក្រសួងបរិស្ថានសំរេចបានកន្លងមក វាជាមោទនភាពឈោសក្នុងការរួមចំណែកធានាសុវត្ថិភាពបរិស្ថាន និងជាសេនាធិការអោយរាជរដ្ឋាភិបាល ក្នុងការផ្តួចផ្តើមគំនិតលើកឡើងគោលនយោបាយឬគោលការណ៍ ក៏ដូចជាវិធានការណែនាំនិងដឹកនាំវិស័យបរិស្ថាន ហើយក្រសួងបរិស្ថានក៏បានរៀបចំផែនការយុទ្ធសាស្ត្រនិងយុទ្ធវិធីសំខាន់ៗទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិដើម្បីបុព្វហេតុបរិស្ថានមានដំណើរប្រព្រឹត្តិទៅដោយនិរន្តរភាពក្នុងការអភិវឌ្ឍន៍។

ប្រាកដណាស់ តាមទស្សនៈរបស់អ្នកទស្សនៈវិទូបានអះអាងថា គ្រប់ការងារទាំងអស់អាចអនុវត្តន៍បានសំរេចជោគជ័យត្រូវមានកត្តាពីរជាសារវ័ន្តជួយគាំទ្រគឺកត្តាសត្យានុម័ត និងអត្តនោម័ត ។ កត្តាអត្តនោម័ត គឺសំដៅលើសកម្មភាពមនុស្សដែលរួមមានបុគ្គលដោយឡែកម្នាក់ៗ ឬក្រុមមនុស្សមួយក្រុម ឬអាចឈានដល់សង្គមមនុស្សទាំងមូលដែលមានមនុស្សជាអ្នកដឹកនាំនិងអ្នកត្រូវបានគេដឹកនាំ ។ ចំណែកឯ កត្តាសត្យានុម័ត គឺកត្តាជះឥទ្ធិពលពីខាងក្រៅដែលក្នុងបញ្ហាបរិស្ថាន យើងអាចនិយាយពីកត្តាស្ថានភាពនយោបាយ ស្ថានភាពសេដ្ឋកិច្ច-សង្គម ឬការជះឥទ្ធិពលពីប្រទេសជិតខាងពីប្រទេសក្នុងតំបន់ ឬបណ្តាប្រទេសក្នុងក្របខ័ណ្ឌសាកលលោកទាំងមូលផងដែរ ។ ជាមួយគ្នានេះផងដែរ យើងត្រូវទទួលស្គាល់ថាបើគ្មានអតីតកាល គឺប្រាកដជាគ្មានបច្ចុប្បន្នកាល ហើយក៏មិនអាចមានអនាគតកាលដែរ ។ ព្រោះបច្ចុប្បន្នកាលជាការទទួលបន្តពីអតីតកាល ហើយអនាគតកាលគឺជាលទ្ធលនៃការកសាងឡើងរបស់មនុស្សក្នុងពេលបច្ចុប្បន្នកាល ។

ដូច្នេះ ដំណោះស្រាយបញ្ហាបរិស្ថានដែលយើងកត់សំគាល់ឃើញនៅមានឧបសគ្គខ្លះៗពេលនេះ មិនចំណុះលើឆន្ទៈអត្តនោម័តរបស់បុគ្គលណាមួយឬក្រុមមនុស្សមួយក្រុមណានោះឡើយ គឺត្រូវមានកត្តាជុំវិញជាកត្តាសត្យានុម័តជួយជុំរុញផងទើបធានាបានជោគជ័យក្នុងកិច្ចការពារគ្រប់គ្រង និងអភិវឌ្ឍន៍ដោយនិរន្តរភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា។

ក្រសួងបរិស្ថានសង្ឃឹមថា ឆ្នាំ ២០០៤ និងឆ្នាំបន្តបន្ទាប់ ស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាប្រាកដជាត្រូវបានស្តារឡើងវិញទាំងគុណភាព និងបរិមាណ ហើយលទ្ធផលនៃការខិតខំអប់រំផ្សព្វផ្សាយបណ្តុះបណ្តាលធនធានមនុស្ស និងវិធានច្បាប់នានាដែលក្រសួងបរិស្ថានសំរេចបានកន្លងមកនឹងទទួលបានការគាំទ្រនិងការចូលរួមអនុវត្តន៍យ៉ាងសកម្មពីប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់ឋានៈសង្គម។

មនុស្សខ្មែរគ្រប់រូបត្រូវមានទស្សនៈថាកិច្ចការពារបរិស្ថាន គឺជាភារកិច្ចរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ហើយមនុស្សគ្រប់រូបរស់នៅត្រូវការគុណភាពបរិស្ថានល្អដែលជាកត្តាមួយសារវ័ន្តរួមផ្សំជាមួយកត្តាសង្គមផ្សេងៗទៀត ដើម្បីសុភមង្គល និងសេចក្តីសុខក្នុងការរស់នៅ ហើយធនធានធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបពុំមែនជាកម្មសិទ្ធិផ្តាច់មុខរបស់ជនណាម្នាក់ឬក្រុម មនុស្សមួយក្រុមណាឡើយ ។

**ក្រសួងបរិស្ថាន**

# ពិធីប្រារព្ធសន្និបាតបូកសរុបការងារបរិស្ថានឆ្នាំ ២០០៣ និងទិសដៅអនុវត្តន៍ការងារបរិស្ថានឆ្នាំ ២០០៤




ឯកឧត្តម ស.ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអញ្ជើញជាអធិបតីក្នុងពិធីសន្និបាតបូកសរុបការងារបរិស្ថាន

ឆ្នាំ2003 កន្លងមកជាឆ្នាំទី10ដែលក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចបំពេញបេសកកម្មការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងការបំពេញបេសកកម្ម ដែលមានវិសាលភាពគ្របដណ្ដប់ទូទាំងប្រទេសលើ ៣ ផ្នែកធំៗ គឺ:

-ទី1 ការការពារ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ

-ទី2 ការរួមចំណែកការពារនិងថែរក្សាបរិស្ថានសង្គម-វប្បធម៌ជាតិ និង

-ទី3 ការចូលរួមគាំពារបរិស្ថានមនុស្សដែលក្នុងនោះមានការចូលរួមគាំពារសុខមាលភាព ជាសុកភាព និងការលើកកំពស់ជីវភាព និងគុណភាពជីវិតរស់នៅរបស់ប្រជាជន ។

ដើម្បីធានាប្រសិទ្ធភាពក្នុងការដឹកនាំអនុវត្តន៍ ភារកិច្ចធំៗទាំង3 ខាងលើ និងដើម្បីប្រមូលផ្ដុំបញ្ញាញាណក្នុងការរួមចំណែកដោះស្រាយបញ្ហាទាំងនោះឱ្យបានជោគជ័យសំរាប់ឆ្នាំ 2004 និងឆ្នាំបន្តបន្ទាប់ នាថ្ងៃ25 និងថ្ងៃ26 ខែកុម្ភៈ ឆ្នាំ2004 ក្រសួងបរិស្ថានបានប្រារព្ធរៀបចំសន្និបាតបូកសរុបការងារបរិស្ថាន ដែលមានដំណើរប្រព្រឹត្តទៅយ៉ាងអធិកអធម និងសំរេចបានលទ្ធផលតាមសំណូមពរជាទីមោទនៈ ដោយមានការអញ្ជើញចូលរួមពីតំណាងស្ថាប័នក្រសួងពាក់ព័ន្ធ ពីអាជ្ញាធរដែនដីខេត្ត-ក្រុង និងមន្ត្រីទទួលបន្ទុកដឹកនាំផ្នែកជំនាញបរិស្ថាន ។

ក្នុងឱកាសបិទសន្និបាត ឯកឧត្តម **ស.ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតី ដែលជាមហាកិត្តិយសក្នុងការប្រារព្ធពិធីជាប្រវត្តិសាស្ត្រនោះ ។

ថ្លែងក្នុងសុន្ទរកថាបើកសន្និបាត ឯកឧត្តមបណ្ឌិត **ម៉ុក_ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងសមាជិកសមាជិកានៃអង្គសន្និបាត ដែលបានអញ្ជើញចូលរួមតាមការគោរពអញ្ជើញ និងអញ្ជើញរបស់ក្រសួងបរិស្ថាន ។

ក្នុងសុន្ទរកថានាឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រីបានមានប្រសាសន៍វាយតម្លៃថា"...

*ខ្ញុំសូមប្រកាសជាឧឡារិកក្នុងឱកាសនេះថា លទ្ធផលការងារដែលក្រសួងបរិស្ថានសំរេចបានជោគជ័យនៃបណ្តាឆ្នាំកន្លងមក ជាពិសេសលទ្ធផលក្នុងឆ្នាំ2003នេះ ជាសមិទ្ធផលរួមដែលមិនអាចកាត់ផ្តាច់បានពីកិច្ចសហការនិងសហប្រតិបត្តិការល្អពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ពីកងកម្លាំងប្រដាប់អាវុធ ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងការជួយជ្រោមជ្រែងថវិកា និងសំភារៈពីរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត ពីសប្បុរសជនជាតិ និងអន្តរជាតិនានា ពិសេសគឺការចូលរួមទាំងស្មារតី និងកម្លាំងកាយ ចិត្តរបស់មហាជនយើងគ្រប់មជ្ឈដ្ឋានដែលជាកម្លាំងចលករយ៉ាងសំខាន់បំផុតមិនអាចខ្វះបាន ។*

នាឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានបញ្ជាក់ផងដែរថា:...

*ក្រសួងបរិស្ថានមានមោទនភាពណាស់ក្នុងការសំរេចបានជោគជ័យនេះ ។ តែទោះបីដូច្នេះក៏ដោយ ក៏ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានខេត្ត-ក្រុងនៅមានជួបការលំបាកស្មុគស្មាញជាច្រើនទៀតទាំងផ្នែកធនធានមនុស្ស ធនធានថវិកា ធនធានសម្ភារៈ និងបច្ចេកទេស ដើម្បីធានាអនុវត្តន៍បានជោគជ័យ100% តាមផែនការឆ្នាំ2003ក្នុងកិច្ចប្រតិបត្តិការធានារក្សាសន្តិសុខបរិស្ថានបានគ្រប់ជ្រុងជ្រោយ ។ ដូច្នេះក្នុងកិច្ចពិភាក្សា និងបទអន្តរាគមន៍ពេលខាងមុខនេះ ខ្ញុំសូមសមាជិក សមាជិកាអង្គសន្និបាតទាំងអស់ចូលរួមលើកឡើងមតិអោយបានផុលផុស ដើម្បីរកអោយ ឃើញចំណុចខ្លាំង និងចំណុចខ្សោយជាបទពិសោធន៍ ព្រមទាំងអនុសាសន៍នានាសំរាប់អនុវត្តន៍ ឆ្នាំ2004នេះអោយមានប្រសិទ្ធភាព ។*



ឯកឧត្តមអនុរដ្ឋលេខាធិការ ភ្ញៀវកិត្តិយស និងសមាជិកសមាជិកានៃអង្គសន្និបាតបានតាមដានស្តាប់របាយការណ៍ដោយស្មារតីយកចិត្តទុកដាក់ខ្ពស់

ជាការលើកទឹកចិត្តដល់មន្ត្រីបរិស្ថានក្រោមឱវាទ ឯកឧត្តមបានសំដែងនូវការចាប់អារម្មណ៍ថា"...

*ក្នុងឱកាសដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅនេះដែរ ជំនួសមុខអោយថ្នាក់ដឹកនាំក្រសួងបរិស្ថានគ្រប់លំដាប់ថ្នាក់ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចតាមផ្នែកជំនាញរបស់មន្ត្រីចំណុះអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន និងមន្ទីរបរិស្ថានខេត្ត-ក្រុងទាំង24 ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចដណ្តើមបានជោគជ័យធំៗ ជូនជាតិមាតុភូមិ ឆ្នាំ 2003 កន្លងមក ទោះបីក្នុងកិច្ចដំណើរការសកម្មភាពរបស់ខ្លួនបានជួបប្រទះនូវការខ្វះខាតទាំង ថវិកា សម្ភារៈ និងមធ្យោបាយផ្សេងៗយ៉ាងណាក៏ដោយ ។ ទាំងអស់នេះជាការលះបង់យ៉ាងខ្ពស់ និងប្រកបដោយការច្នៃប្រឌិតយ៉ាងប៉ិនប្រសប់របស់មន្ត្រីបរិស្ថាន ដែលខ្ញុំសូមសំដែងនូវការកោតសរសើរ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតមិនអាចមើលរំលងបាន ចំពោះឯកឧត្តម អស់លោក លោកស្រីទាំងអស់ ។*



**ឯកឧត្តមបណ្ឌិត ម៉ុក-ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន ថ្លែងសុន្ទរកថានិងចំណាប់អារម្មណ៍ក្នុងអង្គសន្និបាត**

ក្នុងឱកាសនៃកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ និង បទអន្តរាគមន៍ ឯកឧត្តម លោក-លោកស្រី អភិបាល អភិបាលរងខេត្ត-ក្រុង លោក-លោកស្រីតំណាងក្រសួង មន្ទីរពាក់ព័ន្ធ និងមន្ត្រីបរិស្ថានបានផ្តោតអារម្មណ៍ជាខ្លាំងលើកិច្ចការពារធនធានធម្មជាតិ, ភាពអសកម្មនៃបទល្មើសព្រៃឈើក្នុងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងសំណល់គ្រប់ប្រភេទ ។ អង្គសន្និបាតក៏បានលើកឡើងនូវសំណូមពរមួយចំនួនដើម្បីស្នើអោយក្រសួង និងរាជរដ្ឋាភិបាលជួយដោះស្រាយក្នុងគោលបំណងធានាការគ្រប់គ្រងបរិស្ថាន អោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយអង្គសន្និបាតបានគាំទ្រលើចំណុចវិជ្ជមានដែល ក្រសួងបានដឹកនាំអនុវត្តន៍ប្រកបដោយជោគជ័យកន្លងមក។



**ឯកឧត្តម ឆាន់-សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថានធ្វើបទអន្តរាគមន៍និងលើកឡើងនូវអនុសាសន៍មួយចំនួនក្នុងការបំពេញភារកិច្ចការពារបរិស្ថាន**

ជាអធិបតីក្នុងពិធីប្រារព្ធបិទសន្និបាត ឯកឧត្តម **ស-ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមានមតិសំណេះសំណាលប្រកបដោយខ្លឹមសារ និង អត្ថន័យយ៉ាងជ្រាលជ្រៅ ហើយឯកឧត្តមក៏បានផ្តល់អនុសាសន៍លើចំណុច សំខាន់ៗមួយចំនួន ។



## ឯកឧត្ដម ស_ខេង បានទទួលបដិសណ្ឋារកិច្ចពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងភ្ញៀវកិត្តិយស នាឱកាសអញ្ជើញដល់ទីស្ដីការក្រសួងបរិស្ថាន

ក្នុងវគ្គមួយនៃសុន្ទរកថាបិទសន្និបាត ឯកឧត្ដមបាន មានប្រសាសន៍ថា"...

*តាមរបាយការណ៍ដែលថ្លែងដោយឯកឧត្ដម បណ្ឌិត* ***ម៉ុក_ម៉ារ៉េត*** *ពីលទ្ធផលរបស់អង្គសន្និបាត ខ្ញុំបានពិនិត្យឃើញថា សន្និបាតរបស់យើងទទួលបានលទ្ធផលជាផ្លែផ្កា ហើយសមាជិកនៃអង្គសន្និបាត បានផ្លាស់ប្តូរយោបល់គ្នាយ៉ាងផុលផុស ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីជំនះនូវឧបសគ្គ និងរិះរកគន្លឹះដោះស្រាយបញ្ហាអវិជ្ជមាននានា ដែលបានជួបប្រទះនាឆ្នាំកន្លងមក ។ ក្រសួងបរិស្ថាននិងមន្ទីរបរិស្ថានខេត្ត-ក្រុង នៅមានការខ្វះខាតជាច្រើនទៀតដោយកត្តាសត្យានុម័ត និងអត្តនោម័តក្នុងការបន្តអនុវត្តន៍បេសកកម្មរបស់ខ្លួន ។ ខ្ញុំទទួលយករាល់សំណូមពរដែលសន្និបាតបានលើកឡើង ដើម្បីបុព្វហេតុបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាមានភាពស្រស់បំព្រងជានិច្ច និងមានគុណភាពល្អសម្រាប់ទ្រទ្រង់ សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។*

ក្នុងឱកាសនោះដែរ ឯកឧត្ដមក៏បានអះអាងថា

*បើពិនិត្យលើភាពជាក់ស្តែងនៅកម្ពុជា រាជរដ្ឋាភិបាលក៏ដូចក្រសួងបរិស្ថានមិនបានបណ្តែតបណ្តោយអោយបទល្មើសពាក់ព័ន្ធនឹងការងារបរិស្ថានបានរួចផុតពី "សំណាញ់នៃច្បាប់ឡើយ " ប៉ុន្តែបទល្មើសទាំងនោះចេះតែកើតមានជាបន្តនៅកន្លែងមួយ ចំនួនដែលត្រូវតែមានវិធានការទប់ស្កាត់ឱ្យទាន់ពេលវេលា ។*

ជាការឆ្លើយតបសំណូមពរនៃសន្និបាត ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី បានលើកឡើងនូវអនុសាសន៍មានលក្ខណៈជាយុទ្ធសាស្ត្រចំនួន 11 ចំណុចសំរាប់យកទៅអនុវត្តន៍ ។

**ក្នុងអនុសាសន៍ទី១ ទាក់ទងនឹងការងារគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ ឯកឧត្ដម** ឧបនាយករដ្ឋមន្ត្រីបានមាន**ប្រសាសន៍ថា:**

*កន្លងមក មានជនឱកាសនិយមមួយចំនួនតូចបាន*

*វាគទីយកតំបន់ឆ្នេរសមុទ្រធ្វើជាកម្មសិទ្ធិ នាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានតំបន់ឆ្នេរ និងរំលោភលើច្បាប់នានាជាធរមាន ។ យោងតាមអនុសាសន៍របស់ សម្ដេចនាយករដ្ឋមន្ត្រី* ***ហ៊ុន សែន*** *ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរមូលដ្ឋានត្រូវពង្រឹងការអនុវត្តន៍ច្បាប់ ដោយត្រូវចាត់វិធានការលុបបំបាត់ភាពអនាធិបតេយ្យនៅតំបន់ឆ្នេរឱ្យខាងតែបាន ។ បើបច្ចុប្បន្ននេះ យើងដោះស្រាយភាពអនាធិបតេយ្យទាំងនោះមិនបានសំរេចទេ នោះអនាគតនឹងផ្ដល់នូវផលវិបាកយ៉ាងច្រើនទាក់ទងដល់ការអភិវឌ្ឍន៍តំបន់ឆ្នេរឱ្យក្លាយទៅជាតំបន់ទេសចរណ៍ធម្មជាតិ និងជាតំបន់អភិវឌ្ឍន៍ដោយចីរភាពធានាបានកិច្ចការពារបរិស្ថាន ។*

អង្គសន្និបាតបានតាមដានស្ដាប់សុន្ទរកថា មតិសំណេះសំណាល និងអនុសាសន៍ទាំង ១១ចំណុចដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ។

សន្និបាតបានបញ្ចប់នាម៉ោង 17 ប្រកបដោយជោគជ័យក្នុងបរិយាកាសរីករាយ ស្និទ្ធស្នាល និងក្នុងស្មារតីសហការ សហប្រតិបត្តិការ ការរិះគន់ស្ថាបនា ការយោគយល់គ្នា ព្រមទាំងសាមគ្គីភាពល្អក្នុងឧត្ដមគតិ តែមួយគឺការការពារធនធានធម្មជាតិ និងបុព្វហេតុការពារ ថែរក្សាគុណភាពបរិស្ថាន ព្រះរាជាណាចក្រកម្ពុជា អោយគង់វង្សល្អសំរាប់ទ្រទ្រង់សុខមាលភាព និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនអោយបានកាន់តែប្រសើរនិងខ្ពង់ខ្ពស់ជាងមុន ។

ពិធីបិទសន្និបាតបានបញ្ចប់ បន្ទាប់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រីបំពាក់គ្រឿងឥស្សរិយយស ជូនមន្ត្រីបរិស្ថានមានស្នាដៃការងារល្អ នាឆ្នាំ2003កន្លងមក ។!

រូបថតនិងអត្ថបទ: **នាយកដ្ឋានអប់រំ ពត៌មាន និងផ្សព្វផ្សាយបរិស្ថាន**

## <u>មនុស្សជាតិ ត្រូវរួបរួមគ្នា ការពារបរិស្ថានភពផែនដី:</u>

មាតុបរិស្ថានរបស់មនុស្សជាតិ គឺភពផែនដី ។ សព្វថ្ងៃនេះ ផែនដីយើងកាន់តែមានភាពទ្រុឌទ្រោម និងមានជម្ងឺ ក្នុងការខិតខំចិញ្ចឹមកូនចៅជាមនុស្សជាតិដែលមានចំនួន យ៉ាងច្រើនលើសលប់ ។ ក្នុងពេលដែលធនធានទ្រទ្រង់ជីវិតសត្វលោក ព្រមទាំងសមត្ថភាពស្តារឡើងវិញរបស់វាកំពុងតែចុះខ្សោយ ភពផែនដីកាន់តែមានមនុស្សច្រើនឡើង ហើយវាក៏ទទួលរងនូវការបំពុលផងដែរ ។

ដូច្នេះ ភពផែនដីមានសំណូមពរយ៉ាងទទូច និងជាបន្ទាន់អោយស្ថាប័នរដ្ឋបាលគ្រប់លំដាប់ថ្នាក់ជួយព្យាបាលជម្ងឺវា ហើយវាក៏ត្រូវការអ្នកព្យាបាលដែលមានភក្តីភាពបំផុតចំពោះវា ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ ០៦៩ សជណ ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ២០០៤

# **អនុសាសន៍របស់**

## **សន្និបាតបូកសរុបការងារបរិស្ថានឆ្នាំ ២០០៣**

## **និងទិសដៅការងារបរិស្ថានឆ្នាំ ២០០៤**

កាលពីថ្ងៃទី ២៥និង២៦ ខែកុម្ភៈ ឆ្នាំ ២០០៤ នៅសាលប្រជុំទីស្តីការក្រសួងមានប្រារព្ធពិធីសន្និបាតបូកសរុបការងារបរិស្ថានឆ្នាំ ២០០៣ និងលើកទិសដៅការងារបរិស្ថានឆ្នាំ ២០០៤ ។

វត្តមានចូលរួមជាសមាជិក សមាជិការអង្គសន្និបាតរួមមានអភិបាល អភិបាលរង គ្រប់ខេត្ត-ក្រុង ប្រធាន អនុប្រធាន អង្គភាពចំពោះទីស្តីការក្រសួង បរិស្ថាន តំណាងក្រសួងពាក់ព័ន្ធ និងអង្គការអន្តរជាតិ.......... ។

បន្ទាប់ពីបានស្តាប់របាយការណ៍ សមាជិក សមាជិការអង្គសន្និបាត បានធ្វើបទអន្តរាគមន៍ជាបន្តបន្ទាប់ពាក់ព័ន្ធទៅ នឹងសមត្ថកិច្ចជំនាញបរិស្ថានតាមខេត្ត-ក្រុង នីមួយៗ ។

**ឯកឧត្តមបណ្ឌិតម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធានគណៈអធិបតីនៃអង្គសន្និបាតបានដោះស្រាយជាបន្តបន្ទាប់នូវសំណូមពររបស់សន្និបាត ដែលមានជាអនុសាសន៍ដូចតទៅ :-

### I-**<u>អំពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ តំបន់ការពារឧទ្យានជាតិ តំបន់ទេសភាព តំបន់ដីសើម និងការគ្រប់គ្រងសហគមន៍ តំបន់ការពារធម្មជាតិ :</u>**

**១. អំពីការកិច្ចរួម:**

- ត្រូវបន្តជំរុញការបង្កើតសហគមន៍ការពារធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិទាំង ២៣ ក្នុងទូទាំងប្រទេស ព្រោះនេះជានយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការការពារសម្បត្តិធម្មជាតិ របស់ ជាតិប្រកបដោយចីរភាព ។

- ត្រូវបន្តពង្រឹងការងារដឹកនាំ និង គ្រប់គ្រងរបស់សហគមន៍ក្នុងការអនុវត្តន៍ច្បាប់ ។ កិច្ចការនេះប្រធានតំបន់ការពារធម្មជាតិនីមួយៗជាអ្នកទទួលខុសត្រូវសំខាន់ប្រធានត្រូវចុះជាប់ជាប្រចាំតាមសហគមន៍ នីមួយៗ។

-ចំពោះបទល្មើសរំលោភបំពានមកលើដែនតំបន់ការពារធម្មជាតិ ប្រធានតំបន់ការពារធម្មជាតិត្រូវរាយ

២-ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលបានបង្កើតហើយឱ្យកាន់តែមាន ដំណើរការល្អប្រសើរ។ មន្ទីរជំនាញបន្តសហការថែមទៀត ជាមួយនាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ ដើម្បីអប់រំសមាជិកសហគមន៍ឱ្យកាន់តែយល់ដឹងថែមទៀត អំពីតួនាទីរបស់សហគមន៍ ជៀសវាងសមាជិកសហគមន៍ទៅបំផ្លាញធនធានធម្មជាតិ នូវតំបន់ការពារធម្មជាតិឱ្យរលំទាំងមូល។

**- ចំពោះខេត្តពោធិសាត់ :**

១-តំបន់ថ្មកែវធម្មជាតិ ពុំស្ថិតក្នុងតំបន់ការពារធម្មជាតិ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថានទេ ហើយបច្ចុប្បន្នកំពុងរងការបំផ្លាញដោយអាជីវកម្មអនាធិបតេយ្យ សូមអាជ្ញាធរខេត្តទប់ស្កាត់ឱ្យបានបញ្ហានេះ ដើម្បីពិនិត្យនិង ដោះស្រាយតាមបទដ្ឋានច្បាប់។ អាជ្ញាធរខេត្តបង្កើតគណៈកម្មការចំរុះចុះស្រាវជ្រាវ ឱ្យច្បាស់ដល់ទីកន្លែងពិនិត្យមើលអាជ្ញាប័ណ្ណដែលអាជីវករមាន តើថ្នាក់ណាចេញហើយថវិកាដែលប្រមូលបានសមត្ថកិច្ចណាទទួលខុសត្រូវ។ ក្រោយពិនិត្យច្បាស់លាស់ហើយត្រូវធ្វើរបាយការណ៍ទៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពលនិងមកក្រសួងបរិស្ថាន ដើម្បីក្រសួងទាំងពីររួមគ្នារកវិធានការទប់ស្កាត់ការដាក់មីនបំផ្លាញថ្មកែវដ៏មានតំលៃនេះ។
២-ចំពោះការបន្តសកម្មភាពរបស់ក្រុមហ៊ុនព្រៃសម្បទាន ដែលចប់អាជ្ញាប័ណ្ណស្នើអាជ្ញាធរខេត្តពិនិត្យច្បាស់លាស់ និង រាយការណ៍ជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទពិនិត្យសម្រេច ។

**-ចំពោះខេត្តកំពត:**

១- សូមវាយតំលៃខ្ពស់ចំពោះការខិតខំរបស់អាជ្ញាធរខេត្តកំពត ដែលមាននយោបាយដឹកនាំដល់ការគ្រប់គ្រងឧទ្យានជាតិបូកគោមានការរីកចម្រើន ពិសេសក្នុងការបង្ក្រាបបទល្មើសនិងពង្រឹងសហគមន៍តំបន់ការពារធម្មជាតិ ។ ដោយឡែកមន្ត្រីគ្រប់គ្រងឧទ្យានជាតិត្រូវបន្តសហការ ឱ្យបានល្អថែមទៀតជាមួយរដ្ឋបាលព្រៃឈើ និង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។

២-ត្រូវបន្តពង្រឹងការងារសហគមន៍ជុំវិញឧទ្យាជាតិបូកគោ។ ប្រធានឧទ្យាជាតិមានតួនាទីសំខាន់ក្នុងការដឹកនាំពង្រឹងសហគមន៍ តាមការណែនាំរបស់អាជ្ញាធរខេត្តនិងរបស់ក្រសួង ។ ឧទ្យានុរក្សគ្រប់រូបត្រូវចេះធ្វើខ្លួនឱ្យប្រជាជនស្រឡាញ់។

៣-ចំពោះសំណង់ទាំងអស់ទោះចាស់ឬកំពុងសាងសង់នៅតំបន់ទឹកឈូ គឺជាការសង់លើដីគ្មានប្លង់ទេព្រោះគេសង់សំណង់ខុសច្បាប់លើដីឧទ្យានជាតិដែលជាដីរបស់រដ្ឋ ។រាល់ការរំលោភទាំងអស់មកលើតំបន់ឧទ្យានជាតិត្រូវតែបង្ក្រាបនិងកំទេចចោល។

**-ចំពោះខេត្តស្ទឹងត្រែង :**

១-សូមវាយតំលៃខ្ពស់ចំពោះការប្រើប្រាស់កំលាំងគណៈបញ្ជាការឯកភាពខេត្ត ដើម្បីបង្ក្រាបនិងទប់ស្កាត់នូវរាល់បទល្មើសទទួលបានជោគជ័យ នេះគឺជាបទពិសោធន៍ល្អនៃការប្រើប្រាស់កំលាំងសរុប និងវិធានការសរុបក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។

២- ចំពោះផលប៉ះពាល់ដែលបណ្តាលមកពី ការកសាងទំនប់ទឹកវារីអគ្គីសនីយ៉ាលី របស់ប្រទេសវៀតណាម

គឺក្រសួងកំពុងតែធ្វើការតាមរយៈគណៈកម្មាធិការជាតិទន្លេមេគង្គ ដើម្បីសម្របសម្រួលនិងដោះស្រាយជាមួយភាគីវៀតណាមជាបន្តបន្ទាប់ ។

**-ចំពោះខេត្តសៀមរាប:**

១- អាជ្ញាធរខេត្ត-មន្ទីរបរិស្ថានខេត្តត្រូវមានផែនការធ្វើអនាម័យបន្ថែមនៅទីសាធារណៈ និងជងស្ទឹងសៀមរាប ។ ក្រសួងបរិស្ថានពិសេសនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានរុញឱ្យម្ចាស់សណ្ឋាគារនិងអាជីវករសិប្បករធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ។

២-អាជ្ញាធរខេត្ត ត្រូវតែសហការជាមួយក្រសួងបរិស្ថានការពារតំបន់ការពារធម្មជាតិឱ្យបានល្អ គឺទប់ស្កាត់នូវរាល់បណ្តលបទល្មើសឱ្យបាន ទាន់ពេលវេលា ។ ការកាប់ព្រៃលិចទឹក , ការកាប់ព្រៃឈើ , ការវាតយកដីក្នុងតំបន់ការពារធម្មជាតិ ការសាងសង់ខុសច្បាប់ គឺជាបទល្មើសផ្ទុយនិងច្បាប់ដែលត្រូវតែដោះស្រាយតាមផ្លូវច្បាប់ ។

៣-ត្រូវពង្រឹងការងារបរិស្ថានក្នុងកម្មវិធីសីលា តាមរយៈការពង្រឹងសហគមន៍មូលដ្ឋាននិងក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីទប់ស្កាត់រាល់បទ ល្មើសទាំងនោះនិងលើកកំពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ ។

**-ចំពោះក្រុងព្រះសីហនុ :**

១- មន្ទីរបរិស្ថានត្រូវធ្វើជាសេនាធិការឱ្យអាជ្ញាធរក្រុងដើម្បី ទប់ស្កាត់នូវរាល់បទល្មើសទាំងអស់នៅក្នុងតំបន់ការពារធម្មជាតិ ហើយត្រូវរាយការណ៍ មកក្រសួងជាប្រចាំរាល់បទល្មើសដែលកើតឡើង ។

២-អាជ្ញាធរក្រុងត្រូវជំរុញអនុវត្តសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់ឆ្នេរសមុទ្រក្រុងព្រះសីហនុ លេខៈ ១០សសរ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ។

**-ចំពោះខេត្តបាត់ដំបង :**

១-ចំពោះតំបន់ការពារធម្មជាតិទាំង៤តំបន់ក្នុងទឹកដីខេត្តបាត់ដំបងអាជ្ញាធរខេត្ត និងមន្ទីរបរិស្ថានខេត្តត្រូវជំរុញ និងបង្កើនការទប់ស្កាត់នូវរាល់បទល្មើសនៅព្រៃកទាល់ , សំឡូត , រនាមដូនសំ និងភ្នំសំកុសឱ្យបានសកម្មថែមទៀត ដោយអនុវត្តម៉ឺងម៉ាត់នូវបទដ្ឋានគតិយុត្តិដែលមានជាធរមាន ។

២-ចំពោះសំណើអាវុធសំរាប់ប្រើប្រាស់ក្នុងតំបន់នោះ មន្ទីរបរិស្ថានខេត្ត ជាដំបូងត្រូវទាក់ទងជាមួយអាជ្ញាធរខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ចំពោះការបង្ហូរទឹកកខ្វក់ចូលស្ទឹងសង្កែអាជ្ញាធរខេត្ត ដោយមានមន្ទីរបរិស្ថានជាសេនាធិការសិក្សាលទ្ធភាពកាត់បន្ថយការបង្ហូរទឹកសំអុយចូលក្នុងស្ទឹង ។

## II- អំពីត្រួតពិនិត្យការបំពុលបរិស្ថាន និងការគ្រប់គ្រងសំណល់

**១- អំពីការគ្រប់គ្រងសំណល់:**

រាល់បណ្ដាសំណល់រឹង-រាវ សំណល់ឧស្សាហកម្ម និងបណ្ដាសារធាតុពុលដទៃទៀត នៅតាមខេត្ត-ក្រុង និងទីប្រជុំជនទូទាំងប្រទេសយើងត្រូវគ្រប់គ្រងឱ្យបានល្អ ។ ការទុកដាក់សំណល់រឹង និងសំណល់ឧស្សាហកម្ម ត្រូវរកទីតាំងទុកដាក់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គឺត្រូវមានទីតាំងដែលឆ្ងាយពីតំបន់ប្រជាជនរស់នៅ និងជីករណ្ដៅជ្រៅ និងមានកន្លែងកែច្នៃសំរាម ។ សំណល់រាវដែលមានសារធាតុបំពុល ត្រូវធ្វើអាងចម្រោះតាមលក្ខណៈបច្ចេកទេស មុននិងបង្ហូរចូលលូ . ទន្លេ .បឹងបួរ. ។

**២-ការតិច្ចជាត់ស្ដែងអំពីការគ្រប់គ្រងសំណល់តាមខេត្ត-ក្រុង :**

**-ចំពោះក្រុងភ្នំពេញ :**

១-បន្តសហការជាមួយភាគីជប៉ុន ក្នុងការរៀបចំទីតាំងចាក់សំរាមនៅស្ទឹងមានជ័យ និងកសាងជាតំបន់គំរូ ដើម្បីឱ្យជំនាញបរិស្ថានសិក្សាអំពីការគ្រប់គ្រងសំរាម ។

២-អំពីសំរាមនៅតាមតំបន់ជាយក្រុងហើយ ដែលមិនស្ថិតក្នុងកិច្ចសន្យារបស់ក្រុមហ៊ុនស៊ីនទ្រី នោះអាជ្ញាធរក្រុងត្រូវតែរិះរកវិធានការដោះស្រាយ មិនអាចបណ្ដែតបណ្ដោយ ដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈជន ឡើយ ។

៣-សំណល់ឧស្សាហកម្មនៅតំបន់កាណាឌីយ៉ាបានបង្ហូរតាមលូដែលមានទំហំទទឹង១ម៉ែត្រ គឺវាពុំត្រឹមត្រូវគ្រប់គ្រាន់តាមលក្ខណៈនៅតំបន់នោះទេ។

៤-ការធ្វើអាងចម្រោះមុន និងបង្ហូរចេញទៅតំបន់បឹងត្របែក.បឹងទំពុន.បឹងជើងឯក . បឹងបាយ៉ាប ។ល។ ត្រូវធ្វើឱ្យត្រឹមត្រូវតាមទំរង់បច្ចេកទេស ដើម្បីបន្ថយការបំពុលឱ្យនៅតិចមុនពេលបង្ហូរចូលទៅក្នុងបឹងធម្មជាតិទាំងនោះ ។

៥-គាំទ្រដល់អាជ្ញាធរក្រុងដែលកំពុងសហការជាមួយភាគីជប៉ុនបន្តទៅទៀត ក្នុងការស្ដារប្រឡាយបឹងសាឡាង . ស្ទឹងមានជ័យ . និងបឹងក្រពើ ដើម្បីស្ដារស្ថានភាពនៃការកាត់បន្ថយសារធាតុពុល នេះឱ្យបានឆាប់ ។

**-ចំពោះខេត្តសៀមរាប :**

១-សំណល់ក្នុងខេត្តនាំឱ្យមានការបំពុលដល់ប្រភពទឹកនៅក្រោមដី និងបញ្ហាសុខភាពប្រជាជន ។ ចំពោះបញ្ហានេះអាជ្ញាធរខេត្តត្រូវមានវិធានការទប់ស្កាត់ជាបន្ទាន់ ដោយរៀបចំលិខិតបទដ្ឋានបន្ថែមទៀតណែនាំប្រជាជន . សហគ្រាស . រោងចក្រ . សណ្ឋាគារ . ។ល។ បញ្ឈប់ការបញ្ចេញជាតិបំពុលដោយផ្ទាល់ គឺត្រូវធ្វើអាង ចម្រោះ មុននិងបង្ហូរចេញ ។

២-ចំពោះទឹកស្ទឹងសៀមរាបត្រូវសិក្សា និងមានវិធានការធ្វើយ៉ាងណាឱ្យទឹកស្ទឹងហូរ ដើម្បីចៀសវាងការបំពុលទឹក ។ ករណីចាំបាច់អាជ្ញាខេត្តត្រូវមានទូកសំរាប់ប្រមូលសំរាម ដើម្បីស្រង់យកទៅបោះចោលនៅ

ទីលានចាក់សំរាមដែលបានកំណត់ បើពុំដូច្នោះទេស្ទឹងនេះ អាចរាក់និងផ្ទុកសារធាតុពុលពីសំណល់ពុលគ្រប់ប្រភេទ ។

**-ចំពោះខេត្តកំពង់ចាម :**

១-អំពីទីតាំងសំរាប់ចាក់សំរាមសូមឱ្យអាជ្ញាធរខេត្តរកទីតាំងមួយសមស្របជិតក្រុងឬក្នុងស្រុកកំពង់សៀម ដើម្បីធ្វើទីលានចាក់សំរាម ។

២-ចំពោះសំណូមពរស្តីពីការបង្កើតរោងចក្រដុតសំរាម អាចធ្វើទៅបានដរាបណាបរិមាណសំរាម មានចំនួន ៧00 ទៅ ១000តោនក្នុង១ថ្ងៃ ទើបអាចធ្វើបា ន ។

**-ចំពោះខេត្តកំពង់ឆ្នាំង:**

១- ត្រូវខិតខំដោះស្រាយឱ្យមានទីតាំងចាក់សំរាម ដើម្បីឱ្យប្រជាជនយក សំរាមទៅចាក់នៅទីនោះ ។ បញ្ហានេះ សូមឱ្យអាជ្ញាធរខេត្តដោះស្រាយ ទីតាំងចាក់សំរាម ជាបន្ទាន់ជៀសវាង ការបំពុលបរិស្ថាន ។

២- ចំពោះទស្សនៈដែលចង់ជន្លៀសប្រជាជនចេញពីបឹងទន្លេសាប ឱ្យមករស់នៅលើគោកក្នុងគំនិតដែលថា បញ្ចៀសការបំពុលបរិស្ថានទឹកទន្លេសាបនោះ ក្រសួងបរិស្ថានយល់ថាទស្សនៈនេះ ចង្អៀតចង្អល់ពេក ។ ការគ្រប់គ្រងសំណល់នៅក្នុងបឹងទន្លេសាប ត្រូវបញ្ចូលកម្មវិធីនេះទៅក្នុងកម្មវិធី សីលាដែលមាននៅក្នុងកម្មវិធីការងាររបស់ ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ដូច្នេះជាបណ្តើរៗយើងអាចគ្រប់គ្រង សំណល់រឹងរាវបាន ។ហើយបើចាំបាច់ អាចមានអ្នកមៅការដឹកសំរាមតាមទូក យកទុកនៅទីលានចាក់សំរាមដីគោក ។

**-ចំពោះខេត្តតាកែវ :**

១-ក្រសួងគាំទ្រការគ្រប់គ្រងសំណល់រឹង គឺជាកម្មវត្ថុមួយរបស់ខេត្តដែលបាននិងកំពុងយកចិត្តទុកដាក់ក៏ដូចជាទិសដៅយុទ្ធសាស្ត្ររបស់ខេត្តឆ្នាំ២00៤ ដល់ ២00៦ក្នុងការកាត់បន្ថយថង់ប្លាស្ទិក ឱ្យបានជាអតិបរិមា ។

២-ត្រូវយកចិត្តទុកដាក់សំអាតនៅតំបន់ស្ទឹងសង្កែនិងទីរួមខេត្តឱ្យបានស្អាតជាប្រចាំ ។

## III - <u>**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)**</u>

-ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺ ជាម៉ែត្រសំរាប់វាស់ និងជាបទដ្ឋានគតិយុត្តិសំរាប់ជំរុញ និងធានាអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបរិស្ថាន ។ គំរោងនានាដែលមានចែងនៅក្នុង អនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែឆ្លងកាត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយត្រូវមានការត្រួតពិនិត្យផ្តល់យោបល់ពីក្រសួងបរិស្ថាន ទើបអនុញ្ញាតិឱ្យចាប់ដំណើរការអនុវត្តន៍ ។

-ត្រូវតែធ្វើការណែនាំឱ្យអ្នកវិនិយោគបានយល់ និងជំរុញឱ្យគេធ្វើការពិនិត្យនិងវាយតំលៃហេតុប៉ះពាល់បរិស្ថានផ្ញើមកក្រសួងបរិស្ថាន ។

-សហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ដែលចេញអាជ្ញាប័ណ្ណឱ្យវិនិយោគិន ឱ្យគេជួយជំរុញអំពីការពិនិត្យ និង

វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

-ស្នើគ្រប់មន្ទីរខេត្ត-ក្រុងទាំងអស់ត្រូវផ្តល់ទិន្នន័យមកឱ្យនាយកដ្ឋាន ពិនិត្យនិងវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីឱ្យនាយកដ្ឋានរៀបចំចងក្រងទិន្នន័យ សំរាប់ធ្វើការបែងចែកថ្នាក់វាយតំលៃហេតុប៉ះពាល់ដល់ខេត្ត-ក្រុង ។

**-ទិសដៅឆ្នាំខាងមុខ:**

-ត្រូវបន្តធ្វើការពិនិត្យនិង វាយតំលៃហេតុប៉ះពាល់បរិស្ថានបន្តទៅទៀត ចំពោះរោងចក្រសហគ្រាសដែលនៅមិនទាន់បានធ្វើ ។

-សិក្សាហេតុប៉ះពាល់បរិស្ថានទៅលើតំបន់មានបឹងបួរ បឹងធម្មជាតិនិងអាងស្តុកទឹកធម្មជាតិនៅតំបន់បឹងទំពុន .បឹងជើងឯក. បឹងបាយាប. បឹងក្រពើ. ស្ទឹងមានជ័យ និងអាងស្តុកទឹកធម្មជាតិធំ១៦ទៀតនៅជាយក្រុង ។

## IV- **អំពីការពាក់ព័ន្ធ អន្តរក្រសួង :**

-នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានត្រៀមសហការជាមួយក្រសួងធនធានទឹក និងឧត្តុនិយមដែលបាននឹងកំពុងព្រៀងច្បាប់ស្តីពីតំបន់ដីសើមនោះ ដើម្បីចេញច្បាប់នេះឱ្យបានឆាប់ ។

-នាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ បន្តសហការល្អជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដើម្បីគ្រប់គ្រងតំបន់ការពារធម្មជាតិទាំង ២៣ និងឧទ្យានជាតិទាំងអស់ដោយលុបបំបាត់ចោល នូវបាតុភាពការកាប់បំផ្លាញ ព្រៃឈើ. ការកាប់រានព្រៃលិចទឹក . ការវាតយកដីនៅមណ្ឌលទេសចរណ៍. តំបន់ធ្នេរ. ការបំផ្លាញពូជមច្ឆាជាតិ និងជីវៈចំរុះ ទូទាំងប្រទេសឱ្យបានជោគជ័យ នៅក្នុងឆ្នាំ២០០៤នេះ ។

-នាយកដ្ឋានពិនិត្យនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រៀមសហការជាមួយក្រសួងឧស្សាហកម្មរ៉ែ និងថាមពលត្រូវចុះសិក្សាស្រាវជ្រាវ ដើម្បីគ្រប់គ្រងតំបន់ថ្មកែវឱ្យបានល្អ ។

-ក្រសួងបរិស្ថាននិងក្រសួងទេសចរណ៍គួររៀបចំក្រុមការងារចំរុះមួយ ដើម្បីធ្វើការរួមគ្នាក្នុងការរៀបចំផែនការយុទ្ធសាស្រ្តរួមមួយសំដៅជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិ ។

## V- **អំពីការដឹកនាំរបស់ថ្នាក់អគ្គនាយកដ្ឋានក្នុងក្រសួង :**

**ក- អគ្គនាយកដ្ឋានបច្ចេកទេស:**

អគ្គនាយកនៃអគ្គនាយកបច្ចេកទេសត្រូវដឹកនាំការអនុវត្តន៍អនុសាសន៍នេះ ដោយចាត់តាំងប្រជុំត្រួតពិនិត្យការងារ៦ខែម្តង ។

**-ទិសដៅនាយកដ្ឋានផែនការនិងកិច្ចការច្បាប់ :**

១-បន្តផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តស្តីពី បរិស្ថានលើកទីបីរបស់ក្រសួង បានជ្រួតជ្រាបដល់គ្រប់អង្គភាព និងមន្ត្រីជំនាញ ។

២-បន្តពង្រឹង និងរៀនសូត្រដល់មន្ត្រីបរិស្ថានដែលជាមន្ត្រីនគរបាលយុត្តិធម៌ ។

**- ចំពោះនាយកដ្ឋានការពារ និងអភិរក្សធនធានធម្មជាតិ :**

១-ត្រូវសហការជាមួយអាជ្ញាធរពិនិត្យច្បាស់ចំពោះសំណង់អនាធិបតេយ្យ នៅតំបន់ទឹកឈូទនេះឱ្យទទួលបានជោគជ័យទៅតាមឯកសាររបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធដល់តំបន់ទឹកឈូដែលនៅជាធរមាននៅឡើយ ។

២- ត្រូវចាត់មន្ត្រីចុះទៅជួយរៀបចំសហគមន៍តំបន់ការពារធម្មជាតិរនាមដូនស ។

៣-ជួយទំនាក់ទំនង អំពីការបំពាក់អាវុធដល់មន្ត្រីបរិស្ថាននៅក្នុងតំបន់ការពារធម្មជាតិទាំង៤ នៅខេត្តបាត់តំបង ។

៤- ត្រូវត្រៀមមន្ត្រីជំនាញ ដើម្បីចុះជួយពង្រឹងសហគមន៍តំបន់ការពារធម្មជាតិ ។

**-ចំពោះនាយកដ្ឋានត្រួតពិនិត្យ ការបំពុលបរិស្ថាន**

**១-ត្រូវរៀបចំលិខិតបទដ្ឋានផ្សព្វផ្សាយទូលំទូលាយដល់ស្ថាប័នសាធារណៈដែលបាន** និងកំពុងដំណើរការ **បញ្ចេញសំណល់សារធាតុពុលទាំងនោះ** ឱ្យរៀបចំធ្វើការកាត់បន្ថយការបំពុល តាមលក្ខណៈបច្ចេកទេស ។ **បើអង្គភាពឬ ស្ថាប័នណាដែលពុំព្រមអនុវត្តនោះត្រូវមានវិធានការផ្លូវច្បាប់ ។**

២-ស្របនិងការចុះត្រួតពិនិត្យការបំពុលបរិស្ថានតាមរោងចក្រសហគ្រាស នាយកដ្ឋានត្រូវចុះតាមសណ្ឋាគារនីមួយៗ ដើម្បីមានវិធានការឬរូបមន្តណាដែលត្រូវកាត់បន្ថយបានទាន់ពេល វេលាការបំពុលបរិស្ថាន ។

៣-ត្រូវចុះសិក្សាឱ្យបានច្បាស់ បរិមាណសំណល់រាវដែលចាក់ចូលក្នុងស្ទឹងសង្កែ ដើម្បីលើកផែនការជាមួយខេត្តសុំថវិការរដ្ឋសំអាតសំណល់ទាំងនេះ ។

៤-ធ្វើសេចក្ដីណែនាំគ្រប់អង្គភាពខេត្ត-ក្រុង ធ្វើបញ្ជីសារពើភ័ណ្ឌប្រភពសំណល់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។ទន្ទឹមនេះក៏ត្រូវធ្វើស្ថិតិបរិមាណសំរាមតាមខេត្តនីមួយៗ ដើម្បីយើងមានទិន្នន័យមួយច្បាស់លាស់ ។

**-ចំពោះនាយកដ្ឋានអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន**

-ត្រូវត្រៀមមន្ត្រីបង្គោលសំរាប់ជាគ្រូដើម្បីចុះបង្រៀនជំនាញ និងអប់រំបរិស្ថានតាមខេត្ត-ក្រុង ។

**-ចំពោះនាយកដ្ឋានពិនិត្យអង្កេត និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន**

១-ត្រូវធ្វើរបាយការណ៍ដាក់ជូនក្រសួងអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន រាល់សំណើគំរោងវិនិយោគដែលអាចមានផលប៉ះពាល់បរិស្ថាន ធ្ងន់ធ្ងរ និងអាចប៉ះពាល់ដល់បរិស្ថានសង្គម ។

២-ត្រូវធ្វើការពិនិត្យនិងវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅតាមសណ្ឋាគារ ចាប់ពី ១០០បន្ទប់ឡើងទៅ ។ ចំណែកឯខេត្ត -ក្រុងត្រូវធ្វើការពិនិត្យ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន ចាប់ពី ៦០បន្ទប់ឡើងទៅ ។

**ខ- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

**-ចំពោះនាយកដ្ឋានគ្រប់គ្រងបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស** : ត្រូវពង្រឹងភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការគ្រប់គ្រងរបៀបរបបការងាររបស់មន្ត្រីដឹកនាំគ្រប់មន្ទីរបរិស្ថានខេត្ត-ក្រុង ដើម្បីធានាបានសុវត្ថិភាព

ការងារត្រូវវាយតំលៃលក្ខណៈសម្បត្តិ និងស្នាដៃរបស់មន្ត្រីដឹកនាំតាមគោលការណ៍ នៃមុខងារសាធារណៈប្រចាំឆ្នាំដើម្បីធានាឬ បានរាល់គុណភាពនៃមន្ត្រីទាំងនោះ ។ត្រូវរាយការណ៍ប្រចាំខែអំពីស្ថានភាពមន្ត្រី ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យ និងផ្ដល់អនុសាសន៍ដឹកនាំបន្ត ។

**-ចំពោះនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ**

-ពិនិត្យថវិកានិងប្រេងឥន្ធនៈសំរាប់បេសកកម្មរបស់មន្ត្រីនៃបណ្ដាអង្គភាពជំនាញបច្ចេកទេស ។ ប៉ុន្តែត្រូវតែអនុវត្តដោយហ្មឹងហ្មាត់ នូវសេចក្ដីណែនាំលេខៈ ០៣៣សណនបស្ថ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ ស្ដីពីវិធានការអនុវត្តគោលការណ៍ លើការគ្រប់គ្រងថវិកាចុះបេសកកម្មក្នុង និងក្រៅប្រទេស ។

**គ-មន្ទីរបរិស្ថានខេត្ត-ក្រុង**

- ត្រូវពង្រឹងការគ្រប់គ្រងលើគ្រប់វិស័យការងារក្រោមសមត្ថកិច្ចរបស់ខ្លួន ។ ត្រូវក្ដាប់ឱ្យបានរាល់ការងារទោះបី បទល្មើសក្ដីហើយរាយការណ៍មកក្រសួងឱ្យបានមុនអ្នកសារពត៌មាន ។ បើអ្នកសារពត៌មានដឹងមុនយើង ឬយើងដឹងតាមសារពត៌មាន នោះហើយជាកម្សោយរបស់យើងហើយគុណភាពនៃការដឹកនាំត្រូវវាយតំលៃតាមនេះ ។

-អនុវត្តរបបប្រជុំជាទៀងទាត់ប្រចាំសប្ដាហ៍ប្រចាំខែ និងរាយការណ៍កំណត់ហេតុប្រជុំ មកអគ្គនាយដ្ឋានរដ្ឋបាល .ហិញ្ញវត្ថុ ដើម្បីសរុបជូនថ្នាក់ដឹកនាំក្រសួង ឱ្យបានទៀងទាត់ ។

-ចំពោះមន្ត្រីតំបន់ការពារធម្មជាតិណា ដែលបានប្រព្រឹត្តបទល្មើសប្រធានឧទ្យានជាតិ ត្រូវធ្វើការអប់រំណែនាំ ឬមានវិធានការផ្លូវច្បាប់ ឬសុំមកក្រសួងលប់ឈ្មោះចោលតែម្ដង ។

ទទួលបានអនុសាសន៍នេះស្នើគ្រប់អាជ្ញាធរខេត្ត-ក្រុង គ្រប់បណ្ដាអង្គភាពចំណុះក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធសហការអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**រដ្ឋមន្ត្រី**

ម៉ុក_ម៉ារ៉េត

# សកម្មភាពសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួងបរិស្ថាន ក្នុងបុព្វហេតុគាំពារ ការពារ និង អភិរក្សបរិស្ថាន



ឯកឧត្តមបណ្ឌិត **ម៉ុក-ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម **ខៀវ-មុត** អគ្គនាយកបច្ចេកទេស ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន នាទីក្រុងរ៉ង់ហ្គូរ ប្រទេសមីយ៉ាន់ម៉ា ស្តីពីការអភិវឌ្ឍន៍ដោយនិរន្តរភាពបរិស្ថាន។




ឯកឧត្តមបណ្ឌិត **ម៉ុក-ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈ រវាងក្រសួងបរិស្ថាន និងអង្គការអភិរក្សសត្វព្រៃនៅកម្ពុជាក្នុងការគ្រប់គ្រងដែនជំរកសត្វព្រៃគូលែន-ព្រហ្មទេព ក្នុងខេត្ត ព្រះវិហារ និងកំពង់ធំ ។




ឯកឧត្តម ឆាន់_សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាអធិបតីក្នុងការប្រារព្ធសិក្ខាសាលាស្តីពី សកម្មភាពប៉ះពាល់របស់មនុស្សទៅលើធនធានធម្មជាតិក្នុងតំបន់ថបនីយជីវៈមណ្ឌលបឹងទន្លេសាប (ព្រែកទាល់) (ថ្ងៃទី15 ខែមករា ឆ្នាំ 2004)



ភ្ញៀវកិត្តិយស និង សមាជិក សមាជិកា អង្គសិក្ខាសាលា




ឯកឧត្តម តូ~ហ្គារី រដ្ឋលេខាធិការក្រសួងបរិស្ថានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពីការដាក់ឱ្យ
ប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបរិស្ថានដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថាន
(ថ្ងៃទី12-13 ខែកុម្ភៈ ឆ្នាំ 2003)



ឯកឧត្តម តូ~ហ្គារី ចែកវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ជូនចំពោះសិក្ខាកាមដែលជាមន្ត្រីទទួលបន្ទុក
នគរបាលយុត្តិធម៌របស់ក្រសួងបរិស្ថាន ក្រោយបញ្ចប់វគ្គសិក្សា




ឯកឧត្តម ធឹក~គ្រឿងទុត្តា អនុរដ្ឋលេខាធិការក្រសួងបរិស្ថានអញ្ជើញជាអធិបតីក្នុង
សិក្ខាសិលាស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និង ការអនុវត្តន៍ច្បាប់ការពារដែនជំរកសត្វព្រៃភ្នំសំកុស



ភ្ញៀវកិត្តិយស និងសមាជិកសមាជិកា អង្គសិក្ខាសាលាក្នុងឱកាសប្រារព្ធពិធី



ឯកឧត្តម **ប្រាជ្ញ-ស៊ុន** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្ដីពីការប្រែប្រួលអាកាសធាតុ។




ឯកឧត្តម **ប្រាជ្ញ-ស៊ុន** ចូលរួមជាគណៈអធិបតី ក្នុងសិក្ខាសាលាស្ដីពីយន្តការអភិវឌ្ឍន៍ស្អាត នៅខេត្តសៀមរាប

(ថ្ងៃ11-12 ខែកុម្ភៈឆ្នាំ2004)



ទិដ្ឋភាពរួមនៃអង្គសិក្ខាសាលា



ឯកឧត្ដម អៀម~រ៉ា អនុរដ្ឋលេខាធិការក្រសួងបរិស្ថានអញ្ជើញចុះពិនិត្យស្ថានភាពបរិស្ថាន ការងារនៅតាមបណ្ដារោងចក្រ



ឯកឧត្ដម វត្ថុំ~សណ្ដាប់ អនុរដ្ឋលេខាធិការក្រសួងបរិស្ថានអញ្ជើញអធិបតីស្ដីពីការអប់រំបរិស្ថានក្នុងកម្មវិធីតន្ត្រីធម្មជាតិ នៅទូរទស្សន៍កម្ពុជា

# តើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ មានសារៈប្រយោជន៍អ្វីខ្លះ?

តាមការកត់ត្រាពត៌មានទិន្នន័យដោយមន្ត្រីការិយាល័យសហគមន៍ព្រៃឈើ និងធនធានធម្មជាតិ( ក.សពឈ ធជ) នៃនាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ បានបង្ហាញឱ្យឃើញថា សហគមន៍តំបន់ការពារធម្មជាតិបានចាប់ផ្ដើមកកើតឡើងនៅក្នុងឆ្នាំ១៩៩៩ ពេលដែលរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ ក្នុងនោះការបង្កើតសហគមន៍តំបន់ការពារធម្មជាតិក៏ជាផ្នែកមួយរួមចំណែកអនុវត្តន៍តាមរយៈការចូលរួមរបស់សហគមន៍មូលដ្ឋានលើការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។ ចាប់ពីឆ្នាំ១៩៩៩មក ចំនួនសហគមន៍តំបន់ការពារធម្មជាតិបានកើនឡើងជា លំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសនៅក្នុងឆ្នាំ២០០៣ ដោយមានការសំរបសំរួលរៀបចំពីនាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ និងគំរោង ឬអង្គការផ្សេងៗដែលបានចាប់អារម្មណ៍លើការងារនេះ។ ឆ្លើយតបទៅនឹងតំរូវការចាំបាច់របស់សហគមន៍ នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៣ ក្រសួងបរិស្ថាន បានចេញគោលការណ៍ណែនាំ ស្ដីពីកិច្ចដំណើរការរៀបចំសហគមន៍តំបន់ ការពារធម្មជាតិ លេខ ១២៦ សជណ ប.ស្ថ .កអធ ដែលបានចុះហត្ថលេខាដោយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងទិសដៅជួយ សំរួល និងលើកកំពស់ប្រសិទ្ធភាពនៃការរៀបចំ និងអនុវត្តន៍ របស់សហគមន៍ តំបន់ការពារធម្មជាតិ ។



*ឯកឧត្តម បណ្ឌិត **ម៉ុក-ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម **អ៊ុក-សុខុន** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទនាឱកាសចូលរួមសំណេះសំណាល ជាមួយសហគមន៍តំបន់ការពារជំរកសត្វព្រៃបឹងពែ (កំពង់ធំ-ព្រះវិហារ-សៀមរាប)*

ឆ្លងតាមការវិភាគលើលទ្ធផលនៃការចុះសិក្សាស្វែងយល់ ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិ តាមរយៈការជួបសំភាសន៍ ជាមួយប្រជាសហគមន៍តំបន់ការពារធម្មជាតិ ក្រុមអ្នកសំរបសំរួល និងគណៈកម្មការសហគមន៍ ក្រុមសិក្សាស្រាវជ្រាវទទួលបានពត៌មានផ្សេងៗដែល ទាក់ទងទៅនឹងផលប្រយោជន៍នៃការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដែលរួមមានចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

**-ការចូលរួមទប់ស្កាត់បទល្មើស**

មុនពេលបង្កើតសហគមន៍ សកម្មភាពបទល្មើសលើការប្រើប្រាស់ផល-អនុផលព្រៃឈើ សត្វព្រៃ និងការនេសាទត្រី តែងតែកើតមានជាញឹកញាប់ ទោះបីជាមានការរឹតបន្តឹង ចុះយាមល្បាតពីសំណាក់ឧទ្យានុរក្សយ៉ាងណាក៏ដោយ។ នៅតំបន់មួយចំនួន សកម្មភាពនេះឈានទៅដល់ការបង្កជាជំលោះរវាងឧទ្យានុរក្ស និងអ្នកប្រើប្រាស់(សហគមន៍មូលដ្ឋាន និងអ្នកខាងក្រៅ) រហូតមានការប៉ះពាល់ដល់អាយុជីវិតទៀតផង ដូចជានៅឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសីហនុ "រាម"។ ក្រៅពីនេះ នៅមានជំលោះមួយចំនួនតូចរវាងសហគមន៍ និងសហគមន៍ ដែលកើតមានឡើងដោយសារការប្រជែងដណ្ដើមផលប្រយោជន៍គ្នាតាមរយៈការប្រមូលផល-អនុផលព្រៃឈើ។

ផ្ទុយទៅវិញក្រោយពេលសហគមន៍ត្រូវបានបង្កើតឡើង បទល្មើសទាំងនោះថយចុះជាលំដាប់ ព្រោះថាក្រុមសំរបសំរួលបានស្វែងយល់ពីបញ្ហាជាគន្លឹះក្នុងតំបន់ យកមកធ្វើការពិភាក្សារួមគ្នាជាមួយសហគមន៍ ដើម្បីរកដំណោះស្រាយសមស្របរក្សាបាននូវផលប្រយោជន៍រួមរវាងការអភិរក្ស និងការអភិវឌ្ឍន៍សហគមន៍តាមរយៈការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ជាពិសេសជូរគណៈកម្មការសហគមន៍បានធ្វើការអប់រំ ផ្សព្វផ្សាយណែនាំដល់សមាជិកសហគមន៍របស់ខ្លួន ឱ្យយល់ពីគុណប្រយោជន៍នៃធនធានធម្មជាតិ ចេះស្រឡាញ់ថែរក្សា និងប្រើប្រាស់សមស្រប។ ម្យ៉ាងទៀតគណៈកម្មការសហគមន៍ធ្វើការចុះយាមល្បាតព្រៃទៅតាមលទ្ធភាពនៃកន្លែងនីមួយៗ ពិសេសសមាជិកសហគមន៍ដែលចូលទៅរកអនុផលផ្សេងៗ ពួកគេអាចមើលឃើញអ្នកដែលប្រព្រឹត្តបទល្មើសបានងាយ។ សកម្មភាពទាំងនេះវាបានបង្ហាញពីការរួមចំណែកកាត់បន្ថយបទល្មើសផ្សេងៗនៅក្នុងតំបន់ការពារធម្មជាតិ។

**ការផ្ដល់សិទ្ធិស្របច្បាប់ចលការចូលរួមគ្រប់គ្រងរបស់សហគមន៍មូលដ្ឋាន**

ការប្រមូលផល-អនុផលព្រៃឈើ និងធនធានធម្មជាតិ គឺជាទំលាប់របស់ប្រជាជនដែលរស់នៅក្បែរ និងក្នុងតំបន់ការពារធម្មជាតិតាំងពីដូនតាមក ដូចជាដងជ័រ បោចវល្លិផ្ដៅ បេះផ្លែឈើព្រៃ ជំឡូងព្រៃ បន្លែព្រៃជាដើម សំរាប់បំពេញនូវសេចក្ដីត្រូវការក្នុងជីវភាពប្រចាំថ្ងៃ។ ការប្រើប្រាស់ផល-អនុផលព្រៃឈើទាំងនេះ ពុំមានលក្ខណៈសមស្របឡើយ ពិសេសការចូលប្រើប្រាស់យ៉ាងលើសលប់ពីសំណាក់ប្រជាជនខាងក្រៅតំបន់ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ដូចជា តំបន់ខ្លះលួចកាប់ដើមច្បោះជ័ររបស់សហគមន៍មូលដ្ឋានដែលពួកគាត់បានគ្រប់គ្រងថែរក្សាតាំងពីដូនតាមក។

ក្រោយពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ គណៈកម្មការ និងសមាជិកសហគមន៍មានសិទ្ធិហាមឃាត់ ណែនាំអប់រំដល់ជនល្មើសដែលប្រព្រឹត្តខុសនឹងលក្ខន្តិកៈ ឬផែនការគ្រប់គ្រងរបស់សហគមន៍ ដែលមានការទទួលស្គាល់ពីអាជ្ញាធរដែនដី និងស្ថាប័នជំនាញ។ តាមរយៈនៃការអនុវត្តន៍លក្ខន្តិកៈសហគមន៍ ផែនការគ្រប់គ្រងរបស់សហគមន៍ ព្រមទាំងសេចក្ដីប្រកាសទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន វាជាកត្តាបង្ហាញយ៉ាងច្បាស់លាស់នូវសិទ្ធិស្របច្បាប់របស់សហគមន៍ក្នុងការចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីធានាបាននូវផលប្រយោជន៍រួម ក្នុងទិសដៅរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។



ប្រជាសហគមន៍ តំបន់ការពារធម្មជាតិ ជីឳក បឹងពែ

### ការកសាងសមត្ថភាពយល់ដឹងដល់សហគមន៍មូលដ្ឋាន

ប្រជាជនដែលរស់នៅក្បែរ ឬក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺជាសហគមន៍ជនបទដែលពុំសូវទទួលបាននូវការអប់រំចំណេះដឹងទូទៅប៉ុន្មានទេ ជាពិសេសអ្នកដែលមានអាយុចាប់ពី២០ឆ្នាំឡើង ព្រោះថាតំបន់ទាំងនោះគ្មានសាលារៀន និងឆ្លងកាត់សង្គ្រាមជាញឹកញាប់។ នៅពេលដែលមានការបង្កើតជាសហគមន៍តំបន់ការពារធម្មជាតិ បានធ្វើឱ្យមានដំណើរការពិភាក្សាពិគ្រោះជាញឹកញាប់ រវាងក្រុមសំរបសំរួល គណៈកម្មការ និងសមាជិកសហគមន៍ ដែលសកម្មភាពទាំងនេះវាជាចំណុចចាប់ផ្តើមឱ្យសហគមន៍មូលដ្ឋានមានការពិចារណា និងចេះគិតគូរទៅលើធនធានធម្មជាតិដែលនៅជុំវិញភូមិដ្ឋាន។ ជាពិសេសតាមរយៈការចូលរួមរៀបចំបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈសហគមន៍ ផែនការគ្រប់គ្រង ព្រមទាំងការអប់រំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលផ្សេងៗ បានធ្វើឱ្យសហគមន៍មានឱកាសផ្លាស់ប្តូរយោបល់ ទស្សនៈ និងបទពិសោធន៍រវាងសហគមន៍មួយទៅសហគមន៍មួយ ដែលធ្វើឱ្យពួកគេបានកើនឡើងសមត្ថភាពយល់ដឹងលើការងារចូលរួមគ្រប់គ្រងធនធានធម្មជាតិ។ ទន្ទឹមនឹងនេះ ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនៅកន្លែងមួយចំនួនក៏បានអនុវត្តន៍ផងដែរនូវការអប់រំផ្សព្វផ្សាយផ្សេងៗ ដែលទាក់ទងនឹងការអប់រំសុខភាពអនាម័យ ឬកសិកម្ម អាស្រ័យលើតំរូវការចាំបាច់ និងសមស្របទៅតាមតំបន់នីមួយៗ។

ការបង្កើនឡើងនូវសមត្ថភាពយល់ដឹងដល់សហគមន៍មូលដ្ឋាន វាមានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ និងការអភិរក្សធនធានធម្មជាតិ។ ដូចនេះ ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបានរួមចំណែកក្នុងការកសាងធនធានមនុស្ស តាមសហគមន៍មូលដ្ឋានលើការងារគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ។

### ការបង្កើតនូវមុខរបរសមស្របរួមចំណែកលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន

តាមការវិភាគលើទិន្នន័យ បានបង្ហាញឱ្យឃើញថា គំរោង និងអង្គការមួយចំនួនដែលធ្វើការសំរបសំរួលរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ភ្ជាប់ទៅជាមួយនូវកម្មវិធីអភិវឌ្ឍន៍គ្រួសារក្នុងសហគមន៍ ដើម្បីរួមចំណែកលើកកំពស់ជីវភាពរស់នៅ ។ ជាក់ស្តែងសហគមន៍តំបន់ឆ្នេរដូចជាកោះខ្យង កោះតាង កោះស្រឡៅ បានប្តូរមុខរបរពីការកាប់ឈើព្រៃកោងកាងធ្វើធ្យូង មកជាអ្នកនេសាទ ឬការចិញ្ចឹមត្រី ខ្យង ងាវ អាស្រ័យស្ថានភាពទីតាំងតំបន់នីមួយៗ ។ ក្រៅពីនេះមានសហគមន៍មួយចំនួនបានអនុវត្តន៍កម្មវិធីកសិកម្ម(ការផ្សំជីកំប៉ុស ដាំឈើហូបផ្លែ បន្លែរួមផ្សំ និងការចិញ្ចឹមសត្វ) និងការអប់រំសុខភាពអនាម័យ រួមចំណែកលើកកំពស់សុខមាលភាពរស់នៅរបស់ប្រជាជន ។ សំខាន់ជាងនេះទៅទៀតការធ្វើកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានទំនាក់ទំនងផ្ទាល់ស្អិតរមួតនឹងប្រភពជីវៈចំរុះ ដូច្នេះត្រូវធានាអោយមាននិរន្តរភាពក្នុងការបង្កបង្កើនផលកសិកម្ម ទៅនឹងការគ្រប់គ្រងធនធានព្រៃឈើ ដែលជាប្រភពទឹក ប្រភពផ្តល់ជីជាតិឱ្យដី ។

ជាទូទៅជីវភាពរស់នៅរបស់សហគមន៍តំបន់ការពារធម្មជាតិភាគច្រើន ពឹងផ្អែកលើការប្រមូលផល-អនុផលព្រៃឈើ ដូចជាជងជ័រ រកគ្រាក់ បោចវល្លិ៍-ផ្តៅ កាប់ឬស្សី បេះបន្លែព្រៃ ផ្លែឈើព្រៃ ដំឡូងព្រៃ ទន្ទឹមនឹងការបង្ក បង្កើនផល ។ តាមរយៈការផ្តល់ពត៌មានពីគណៈកម្មការសហគមន៍ ការរកអនុផលព្រៃឈើវាបានរួមចំណែកបំពេញសេចក្តីត្រូវការក្នុងជីវភាពប្រចាំថ្ងៃរបស់សហគមន៍ជនបទ ។ ដូចនេះប្រសិនបើធនធានព្រៃឈើមានការលូតលាស់ល្អ វាអាចធានាបាននូវការផ្គត់ផ្គង់អនុផលព្រៃឈើសំរាប់ការប្រើប្រាស់ដល់សហគមន៍មូលដ្ឋាន ។ ចំណុចទាំងនេះបង្ហាញឱ្យឃើញថាការបង្កើតសហគមន៍តំបន់ការពារធម្មជាតិជាការរួមចំណែកធ្វើឱ្យការគ្រប់គ្រងធនធានធម្មជាតិមានលក្ខណៈប្រសើរឡើង ក៏ដូចជារួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

### ការបង្កើតនូវកិច្ចសហការរវាងឧទ្យានុរក្ស និងសហគមន៍

តាមរយៈការរៀបរាប់របស់ឧទ្យានុរក្ស ក៏ដូចជាគណៈកម្មការសហគមន៍បានបង្ហាញឱ្យឃើញថា មុនពេលរៀបចំបង្កើតជាសហគមន៍តំបន់ការពារធម្មជាតិ ប្រជាជនភាគច្រើនមានទស្សនៈយល់ច្រឡំ មិនពេញចិត្តចំពោះការងារអភិរក្ស ព្រោះពួកគេមិនមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ ផ្ទុយទៅវិញ ការបង្កើតជាសហគមន៍តំបន់ការពារ បានបង្ហាញយ៉ាងច្បាស់ពីសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ដែលមានបង្ហាញនៅក្នុងលក្ខន្តិកៈសហគមន៍ និងផែនការគ្រប់គ្រងព្រៃសហគមន៍ ។ សកម្មភាពនេះបានធ្វើឱ្យប្រជាជនមានទស្សនៈគិតគូរពិចារណាសមស្របលើការងារអភិវឌ្ឍន៍ប្រកបដោយចីរភាព។

*រាល់សកម្មភាពចុះល្បាតរបស់សហគមន៍ តែងតែមានការចូលរួមពីឧទ្យានុរក្ស ។ម្យ៉ាងវិញទៀតនៅក្នុងដំណើរការរៀបចំ សហគមន៍តំបន់ការពារធម្មជាតិនេះ អាជ្ញាធរដែនដី និងស្ថាប័នជំនាញតែងតែបានចូលរួមជានិច្ចនៅក្នុងសកម្មភាពសំខាន់ៗ ដើម្បីផ្តល់នូវការគាំទ្រ លើកទឹកចិត្ត និងចូលរួមផ្តល់យោបលដល់ការគ្រប់គ្រងរបស់សហគមន៍ ។*



### ការចូលរួមអនុវត្តន៍គោលនយោបាយវិមជ្ឈការ

ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ គឺជាយន្តការមួយចូលរួមអនុវត្តន៍ គោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការផ្ដល់សិទ្ធិក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិដល់សហគមន៍មូលដ្ឋាន ពិសេសទាក់ទងទៅនឹងការសំរេចចិត្តលើការប្រើប្រាស់ផល-អនុផលព្រៃឈើ ដូចជាការចូលរួមធ្វើលក្ខន្តិកៈ និងផែនការគ្រប់គ្រង ព្រៃសហគមន៍ រួមទាំងការអភិវឌ្ឍន៍មូលដ្ឋាន។ ម្យ៉ាងវិញទៀត សហគមន៍តំបន់ការពារធម្មជាតិតែងតែមានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដែលមានថ្នាក់ក្រុមគណៈកម្មការ និងទីប្រឹក្សា។ ដែលពួកគាត់ជាអ្នកចូលរួមសម្របសម្រួល និងដោះស្រាយរាល់បញ្ហាដែលកើតមានឡើងក្នុងសហគមន៍។ លើសពីនេះទៅទៀត គណៈកម្មការក៏មានតួនាទីសំខាន់ក្នុងការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ ដើម្បីស្វែងរកការគាំទ្រទាំងផ្នែកបច្ចេកទេស ក៏ដូចជាថវិកាផងដែរ ក្នុងការអភិវឌ្ឍន៍សហគមន៍របស់ខ្លួន ។ ការលើកផែនការអភិវឌ្ឍន៍សហគន៏មិនស្ថិតតែលើការរុករកអនុផលព្រៃឈើ នៃសហគមន៍តំបន់ការពារធម្មជាតិទេ គឺសហគមន៍បានជំរុញអនុវត្តន៍ផែនការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន មានការធ្វើប្រពលវប្បកម្ម កសិកម្ម ការចិញ្ចឹមសត្វ ការធ្វើសិប្បកម្ម ។ល។

សរុបមក ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ គឺជាយុទ្ធសាស្ត្រមួយសំរាប់កែទំរង់ប្រពន្ធ័គ្រប់គ្រងធនធានធម្មជាតិ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់សហគមន៍មូលដ្ឋាន ព្រមទាំងរក្សាបាននូវតំលៃជីវៈចំរុះនៅក្នុងតំបន់ការពារធម្មជាតិ ពោលគឺជាមធ្យោបាយមួយធ្វើឱ្យមានតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍន៍ ។



*ឯកឧត្ដម បណ្ឌិត* **ម៉ុក_ម៉ារ៉េត** *រដ្ឋមន្ត្រីក្រសួងបរិស្ថានដឹកនាំប្រតិភូចុះធ្វើការអប់រំប្រជាសហគមន៍តំបន់ការពារធម្មជាតិ*

**អត្ថបទរៀបរៀងដោយមន្ត្រីការិយាល័យសហគមន៍ តំបន់ការពារធម្មជាតិនៃនាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ**

# បញ្ហាបរិស្ថានធ្ងន់ធ្ងរនៅតំបន់ព្រៃលិចទឹកបឹងទន្លេសាប

## ១. សេចក្ដីផ្ដើម

យោងតាមរបាយការណ៍ស្ដីពីបរិស្ថាន និងការសិក្សាស្រាវជ្រាវរបស់មន្ត្រីរដ្ឋាភិបាល ក៏ដូចជាភ្នាក់ងារអង្គការក្រៅរដ្ឋាភិបាលនិងអង្គការអន្តរជាតិបានវាយតម្លៃថា សម្បត្តិធម្មជាតិនៅក្នុងប្រទេសកម្ពុជាបានទទួលរងនូវការខូចខាតយ៉ាងដំណំក្នុងអំឡុងសង្គ្រាមស៊ីវិលជាងបីទសវត្សកន្លងមកនេះ រួមទាំងសម្បត្តិធម្មជាតិនៅជុំវិញតំបន់បឹងទន្លេសាប ។ បញ្ហាគួរអោយកត់សំគាល់ធនធានធម្មជាតិក្នុងប្រទេសកម្ពុជាត្រូវបានវិនាសអន្តរាយធ្ងន់ធ្ងរនៅអំឡុងទសវត្សឆ្នាំ ៩០ នៅពេលដែលមាតុភូមិកម្ពុជាយើងកំពុងស្ថិតក្នុងដំណាក់កាលចរចាស្វែងរកសន្តិភាពជាមួយក្រុមចលនាតស៊ូរបស់ភាគីខ្មែរផ្សេងៗ និងក្រោយពីដំណាក់កាលបោះឆ្នោតក្នុងអំឡុងឆ្នាំ១៩៩៣ ដើម្បីបង្កើតរាជរដ្ឋាភិបាលសំរាប់ព្រះរាជាណាចក្រកម្ពុជាក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីអង្គការសហប្រជាជាតិ ។

មុនសម័យសង្គ្រាម កម្ពុជាបានកសាងប្រទេសដោយពឹងផ្អែកលើការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្មក៏ដូចជាលើធនធានធម្មជាតិសំខាន់ៗមានជលផល រុក្ខាប្រម៉ាញ់ រ៉ែ ធនធានទឹក...។ល។ ឧទាហរណ៍: ក្នុងទសវត្សទី៦០កម្ពុជាបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិនូវភោគផលកសិកម្មដូចជាស្រូវអង្ករ ត្រី ឈើ កៅស៊ូ ធញ្ញជាតិ...ដោយប្ដូរជារូបិយវត្ថុបរទេសមកវិញ ។ ប៉ុន្តែ ចាប់តាំងពីក្រោយរបបប្រល័យពូជសាសន៍ប៉ុលពតរហូតមកទល់បច្ចុប្បន្នផលិតផលក្នុងស្រុកដែលត្រូវនាំចេញទៅបរទេសពុំមានរូបភាពជាដុំកំភួនឡើយដោយសារទិន្នផលនៃផលិតផលក្នុងស្រុកពុំឆ្លើយតបនឹងតំរូវការរបស់ ប្រជាជនក្នុងស្រុក ។

ពិនិត្យជារួម ផលវិបាកនេះបណ្ដាលមកពីការបំផ្លាញសម្បត្តិបរិស្ថានធម្មជាតិដើម្បីបំរើផលប្រយោជន៍បុគ្គលពុំមានផែនការ និងការទទួលខុសត្រូវច្បាស់លាស់ ។ សេចក្ដីបរិយាយក្នុងរបាយការណ៍នេះ គឺផ្ដោតលើវិស័យបរិស្ថាននៅតំបន់ព្រៃលិចទឹកបឹងទន្លេសាប ជាផ្អែកសំខាន់ទ្រទ្រង់ដល់ការស្ដារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដែលកំពុងប្រឈមទៅនឹងការបំផ្លិចបំផ្លាញ និងឈានទៅរកការរេចរិលបណ្ដាលមកពីសកម្មភាពផ្សេងៗរបស់មនុស្ស ។



*សកម្មភាពបាចបង្ហូរទឹកបឹងដើម្បីចាប់ត្រី*

## ២. សកម្មភាពបង្កការប៉ះពាល់បរិស្ថានតំបន់បឹងទន្លេសាប

មានបញ្ហាជាច្រើនបាននិងកំពុងបង្កការគំរាមកំហែងគួរអោយព្រួយបារម្ភដល់បរិស្ថានធម្មជាតិ បណ្ដាលមកពីការអភិវឌ្ឍន៍មិនមានចីរភាពបណ្ដាប្រទេសរស់តាមដងទន្លេមេគង្គ និងសកម្មភាពរបស់ប្រជាពលរដ្ឋ និងរបស់ជនល្មើសដើម្បីបំពេញ

គោលបំណងផ្ទាល់របស់គេ ។ សកម្មភាពដែលចាត់ទុកថា បាននិងកំពុងបង្កការគំរាមកំហែងនិងឈានទៅរកការបំផ្លាញធនធានបរិស្ថានធម្មជាតិមានដូចតទៅ:

### ក. ការបំផ្លាញព្រៃលិចទឹក

ការកាប់បំផ្លាញព្រៃលិចទឹកតំបន់បឹងទន្លេសាបបានកកើតឡើងជារូបភាពផ្សេងៗ និងមានកំរិតខុសៗគ្នាដូចជា : ធ្វើជាលំនៅដ្ឋានសំរាប់ស្នាក់អាស្រ័យ បង្កើនផ្ទៃដីដាំដុះជាលក្ខណៈគ្រួសារ ឬលក្ខណៈពាក់កណ្តាលឧស្សាហកម្ម គ្រឿងចំហេះឥន្ធនៈអុសធ្យូង គ្រឿងសំណង់និងគ្រឿងសង្ហារឹម ការដុតបំផ្លាញព្រៃលិចទឹកដើម្បីចាប់សត្វ ការប្រើប្រាស់ជាសំរាស់ដើម្បីចាប់ត្រី... ។ល។

### ខ. ការបំពុលទឹក

គុណភាពទឹកបឹងទន្លេសាបនៅតាមបណ្តាទីប្រជុំជនមួយចំនួន ត្រូវបានប៉ាន់ប្រមាណថាកំពុងតែថយចុះជាបណ្តើរៗនៅក្នុងរដូវប្រាំង ដោយសាររងការបំពុលពីសកម្មភាពផ្សេងៗដូចជា : " *ការបោះចោល និងបង្ហូរសំណល់រឹងរាវពីប្រភពបំពុលចូលក្នុងប្រភពទឹក* " ការប្រើប្រាស់ជីគីមីនិងថ្នាំសំលាប់សត្វល្អិតនៅតំបន់កសិកម្ម សកម្មភាពនេសាទនិងការប្រើប្រាស់ឧបករណ៍ពុំស្របច្បាប់ សកម្មភាពអូសលៀសនៅរដូវប្រាំង សកម្មភាពជីករ៉ែនៅតំបន់ប៉ៃលិននិងតំបន់ដីជំរាលនៃខ្សែទឹកខាងលើ ការហូរច្រោះពីតំបន់ជំរាលជិតខាង សកម្មភាពកំពង់ផែ-ចំណតនាវានិងការបង្ហូរប្រេងម៉ាស៊ីនពីនាវាទៅក្នុងប្រភពទឹក និងការបំពុលពីសកម្មភាពអភិវឌ្ឍន៍ផ្សេងៗរបស់ប្រទេសដែលស្ថិតនៅតំបន់លើខ្សែទឹក ។



*សកម្មភាពរស់នៅនិងប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាប*



*គំនរសំរាមដែលប្រជាពលរដ្ឋបោះចោលក្នុងប្រភពទឹក*



*សកម្មភាពប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតរបស់កសិករនៅតំបន់បឹងទន្លេសាប*

ជាក់ស្តែង នៅពាក់កណ្តាលខែមិថុនា ឆ្នាំ ២០០៣ មន្រ្តីនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានបានធ្វើការត្រួតពិនិត្យករណីបំពុលទឹកនៅតំបន់ឆ្នុកទ្រូ និងបានសន្និដ្ឋានពីគុណភាពទឹកនៅតំបន់ឆ្នុកទ្រូដែលកំពុងរងការបំពុលក្នុងរដូវប្រាំង ដោយសារតំរូវការអុកស៊ីសែនដើម្បីប្រតិកម្មជីវៈ (BOD) មានកំរិតលើសស្តង់ដារកំណត់ដោយអនុក្រឹត្យលេខ ២៧ អនក្រ ។

**ឆ. បទល្មើសផ្សេងៗ**

ក្រៅពីការរៀបរាប់ខាងលើ មានសកម្មភាពអដ្ឋិមានជាច្រើនទៀតបានបង្កការបំផ្លាញនិងកំពុងគំរាមកំហែងដល់ធនធានធម្មជាតិនៅតំបន់បឹងទន្លេសាបដូចជា : ការនេសាទត្រីដោយប្រើឧបករណ៍នេសាទខុសច្បាប់និងការនេសាទក្នុងរដូវហាម-ឃាត់ សកម្មភាពលុកទន្រ្ទានរបស់ប្រជាពលរដ្ឋ និងការនេសាទឬប្រម៉ាញ់នៅក្នុងដែនជំរករបស់បក្សីទឹកឬមច្ឆាជាតិ ដែលជាសកម្មភាពល្មើសបំពានទៅលើបញ្ញតិច្បាប់របស់រាជរដ្ឋាភិបាលនិងសេចក្តីប្រកាសរបស់សាមីស្ថាប័នដែលទទួលខុសត្រូវ ។



សកម្មភាពល្មើសច្បាប់ក្នុងការនេសាទត្រី

## ៣. ផលវិបាកនៅលើវិស័យបរិស្ថាន

តាមរយៈសកម្មភាពរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ដែលពឹងផ្អែកលើធនធានបរិស្ថានធម្មជាតិនៅតំបន់បឹងទន្លេសាប ពិសេសការធ្វើអាជីវកម្មលើធនធានធម្មជាតិដោយពុំមានការត្រួតពិនិត្យ និងគ្រប់គ្រងត្រឹមត្រូវ ញ៉ាំងអោយវិស័យបរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់នេះកំពុងប្រឈមនឹងការបំផ្លិចបំផ្លាញគួរអោយព្រួយបារម្ភ និងអាចបង្កវិបត្តិធ្ងន់ធ្ងរដល់មនុស្សជំនាន់ក្រោយ ។

ខាងក្រោមជាបញ្ហាប៉ះពាល់បរិស្ថានដែលបាន និងកំពុងកើតឡើងនៅក្នុងតំបន់បឹងទន្លេសាប :

- ជំរកមច្ឆាជាតិ ជំរកបក្សីទឹកនិងសត្វព្រៃ ត្រូវបានរួញតូច និងឈានទៅរកការបាត់បង់ជាបន្តបន្ទាប់ជាកត្តាបង្កនូវការប៉ះពាល់ធ្ងន់ធ្ងរដល់ការពង-ញាស់ ការរីកធំធាត់របស់មច្ឆាជាតិ និងជាមូលហេតុជំរុញអោយប្រភេទមច្ឆាជាតិ បក្សីទឹក និងសត្វព្រៃមួយចំនួនបន្លាស់ទីទៅរកមជ្ឈដ្ឋានដែលមានលក្ខខ័ណ្ឌរស់នៅសមស្រប ។

- ប្រភេទមច្ឆាជាតិ បក្សីទឹក និងសត្វព្រៃ កំពុងទទួលរងការវិនាសអន្តរាយ និងប្រភេទខ្លះឈានទៅរកការវិនាសផុតពូជ ដោយសារតែសកម្មភាពបំពានច្បាប់ផ្សេងៗរបស់សហគមន៍ និងជនល្មើស ។

- ពីមួយឆ្នាំទៅមួយឆ្នាំតំបន់មាត់ស្ទឹងហូរចូលបឹងទន្លេសាបទទួលនូវបរិមាណកករក្នុងកំរិតមួយគួរអោយព្រួយបារម្ភដែលបណ្តាលមកពីការហូរច្រោះពីតំបន់ខ្សែទឹកខាងលើ ។ ពោលអោយខ្លី មាត់ស្ទឹងហូរចូលបឹងទន្លេសាបរាក់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយផ្ទៃទឹកបឹងទន្លេសាបកាន់តែរីកសាយគ្របដណ្តប់ទៅតំបន់ជិតខាង ជាហេតុធ្វើអោយជន់លិចបង្កជាហាយនៈភាពដល់ដំណាំកសិកម្ម ក៏ដូចជាទ្រព្យសម្បត្តិនិងហេដ្ឋារចនាសម្ព័ន្ធ និងអាយុជីវិតប្រជាពលរដ្ឋស្ទើរជារៀងរាល់ឆ្នាំ ។

- គុណភាពទឹកបឹងកំពុងថយចុះដោយអន្លើៗ ដោយសារទទួលរងការបំពុលពីប្រភពផ្សេងៗដូចមានបញ្ជាក់ជូនខាងលើ ។ ជម្ងឺជាច្រើនទាក់ទងនិងការប្រើប្រាស់ទឹកកខ្វក់ ឬមិនស្អាត បានកកើតឡើងនៅតាមតំបន់មួយចំនួនដូចជា ជំងឺរាគរូស គ្រុនពោះវៀន អាសន្នរោគ ក្អួតចង្អោរ រោល-រមាស់ ... ។ល។

- ការបាត់បង់រុក្ខជាតិនិងព្រៃលិចទឹក ជាការបាត់បង់នូវប្រព័ន្ធប្រព្រឹត្តកម្មសំអាតទឹកតាមបែបធម្មជាតិ (រុក្ខជាតិក្នុងទឹកមាននាទីសំខាន់ក្នុងការស្រូបយកសារធាតុចិញ្ចឹមពីសំណល់រាវដូចជា អាសូត ផូស្វរ...) ។

- **ការបាត់បង់ព្រៃលិចទឹក** ជាការបាត់បង់សមត្ថភាពក្នុងការស្រូបយកឧស្ម័នកាបូនិចពីសកម្មភាពផលិត [illegible]

ឬបញ្ជៀ [illegible]

- **បង្កើនកំដៅទៅលើផ្ទៃទឹកនិងតំបន់ជិតខាង** ។

- បាត់បង់តំបន់ទេសភាពធម្មជាតិ ជាកត្តាមួយបង្កការប៉ះពាល់ដល់ទេសចរណ៍តាមផ្លូវទឹកដែលរាជរដ្ឋាភិបាលបច្ចុប្បន្នបានកំណត់អាទិភាពខ្ពស់ដល់វិស័យទេសចរណ៍ គឺជាការអភិវឌ្ឍន៍ឧស្សាហកម្មគ្មានផ្សែង និងជាក្បាលម៉ាស៊ីនដឹកនាំសេដ្ឋកិច្ចជាតិទាំងមូល ។

### ៤. សន្និដ្ឋាន

ជាការសន្និដ្ឋានរួម ឥទ្ធិពលប៉ះពាល់បំផ្លាញបរិស្ថាន និងសម្បត្តិធនធានធម្មជាតិបឹងទន្លេសាបកាន់តែវិវត្តគួរអោយព្រួយបារម្ភ ជាបុព្វហេតុជំរុញអោយគុណភាពបរិស្ថាន និងធនធានធម្មជាតិឈានទៅរកការបាត់បង់ទាំងស្រុង ប្រសិនបើបញ្ហាប្រទេសរស់តាមដងទន្លេមេគង្គទាំង៦ និងបើគ្មានវិធានការទប់ស្កាត់ និងកែលំអឡើងវិញអោយទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។

ឆ្លើយតបនឹងការថយចុះនៃគុណភាពទឹក និងបរិស្ថាននៅតំបន់បឹងទន្លេសាបបច្ចុប្បន្នគណៈកម្មការជាតិទន្លេមេគង្គ ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ រួមទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងក្រៅស្រុក បានខិតខំព្យាយាមទប់ស្កាត់កាត់បន្ថយ និងបំបាត់នូវរាល់សកម្មភាពបង្កអោយមានការបាត់បង់គុណភាពបរិស្ថាន និងធនធានធម្មជាតិតាមរយៈយន្តការ-វិធានការជាច្រើន ដោយមានទាំងបរិធានច្បាប់របស់រាជរដ្ឋាភិបាលមួយចំនួនផង ។ ទោះបីយ៉ាងណាក៏ដោយ ការអនុវត្តន៍នេះអាចសំរេចជោគជ័យបានតាមការគ្រោងទុក ត្រូវទាមទារអោយមានការចូលរួមយ៉ាងផុលផុសនិងស្មោះស្ម័គ្រពីសំណាក់សាធារណៈជន និងស្ថាប័នឬ បុគ្គលពាក់ព័ន្ធ ។

*រៀបរៀងដោយៈ លោក* **ជ្រិន សុខា**

*អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន*

# ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលត្រូវបានញាំញីដោយសង្គ្រាមស៊ីវិលរាប់សិបឆ្នាំមក ហើយជាហេតុធ្វើឱ្យធនធានធម្មជាតិលើវិស័យខ្លះទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរនេះ យើងមិនទាន់និយាយដល់ការខូចខាតដល់ផ្នែកបរិស្ថាន សង្គម-វប្បធម៌ និងធនធានមនុស្សនៅឡើយ ។ នៅឆ្នាំ១៩៩៣ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ទទួលបានការឯកភាពជាតិមកប្រទេសយើងបានប្រកាន់យកគោលនយោបាយប្រកួតប្រជែងតាមបែបទីផ្សារសេរី ដែលជាការផ្ដល់ឱកាសដល់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស ដាក់ទុនវិនិយោគលើគ្រប់វិស័យ ដើម្បីរួមចំណែកក្នុងការស្ដារ និងអភិវឌ្ឍន៍ប្រទេសជាតិ ។

ជាការពិតណាស់ថា ការអភិវឌ្ឍន៍ប្រទេសជាតិ ជាប្រការមួយសំខាន់មិនអាចខ្វះបាន សំរាប់ការ ស្ដារសេដ្ឋកិច្ចជាតិ និងការលើកកំពស់ក៏រិតជីវភាពរបស់ប្រជាពលរដ្ឋឱ្យប្រសើរឡើង តែការអភិវឌ្ឍន៍ទាំងនោះត្រូវត្រិះរិះពិចារណាជាមុននូវបញ្ហាបរិស្ថាន សំខាន់ពោលគឺហេតុប៉ះពាល់ដែលអាចនឹងកើតមានដល់បរិស្ថាន និងសង្គមក្នុង និងក្រោយពេលប្រតិបត្តិគំរោងអភិវឌ្ឍន៍ទាំងនោះ ។



គណៈប្រតិភូក្រសួងបរិស្ថានដឹកនាំដោយឯកឧត្តម អៀម-រ៉ា អនុលេខាធិការ អមដំណើរដោយលោក ឌា-ជុំម ប្រធាននាយកដ្ឋាន EIA ចុះសិក្សាស្វែងយល់កសិដ្ឋានចិញ្ចឹមក្ដាមរបស់ក្រុមហ៊ុន តាទុយ នៅក្រុងព្រះសីហនុ

ដោយបទពិសោធន៍ជាប្រវត្តិសាស្ត្រ យើងកត់សំគាល់ឃើញថាការអភិវឌ្ឍន៍ គឺជាអាវុធមុខពីរ ដែលអាចផ្តល់នូវលទ្ធផលពីរផ្ទុយគ្នាគឺផលល្អ (Positive Impact) និងផលអាក្រក់ (Negative Impact) ដែលអាចនឹងកើតឡើងពីគំរោងអភិវឌ្ឍន៍នោះ ។ ដើម្បីចូលរួមការពារបរិស្ថាន និងឆ្លើយតបសំណូមពរ នៃនិន្នាការសកលលោកបច្ចុប្បន្ន ក្រសួងបរិស្ថានក៏ត្រូវបានបង្កើតឡើងដើម្បីការពារបរិស្ថាន និងគ្រប គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាពក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ប្រទេសជាតិក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ ។ ក្នុងដំណើរនៃការបដិសន្ធិក្រសួងបរិស្ថាន "ច្បាប់ស្តីពីកិច្ចការពារ**បរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ**"ត្រូវបានបង្កើតឡើងនិងដាក់ឱ្យប្រើប្រាស់ផ្លូវការនាឆ្នាំ១៩៩៦ ដោយព្រះរាជក្រម ។ **ច្បា**[illegible]**នោះជំពូក**៣បានចែងអំពី "ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន" ហើយជំពូកនេះត្រូវអនុវត្តន៍[illegible]**លើគំរោង** និងសកម្មភាព ផលិតកម្ម ដែលមានស្រាប់ ឬកំពុងដំណើរការ និងរាល់[illegible]**ធនរដ្ឋ** និងសាធារណៈ ។ ផ្តើមចេញពីជំពូក៣នៃច្បាប់ស្តីពីកិច្ចការពារ[illegible]**បង្កើតនាយកដ្ឋានអង្កេត** ពិនិត្យការវាយតំលៃហេតុប៉ះពាល់**បរិស្ថាន**[illegible]**មន្ត្រីក្នុងនាយកដ្ឋាន** និងមន្ត្រីពាក់ព័ន្ធដទៃទៀតចំនួនពីរវគ្គ**ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយមានជំនួយឧបត្ថម្ភថវិកា និងបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី** ។ ដោយមានជំនួយឧបត្ថម្ភនេះ គួបផ្សំនិងការប្រឹងប្រែងយកចិត្តទុកដាក់រៀនសូត្រផង ធ្វើការងារដកពិសោធន៍ជាក់ស្តែងផង អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ។ អនុក្រឹត្យនេះមានគោលបំណងគាំទ្រដល់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឱ្យបានសមស្រប និងល្អប្រសើរទូទាំងព្រះរាជាណាចក្រកម្ពុជា និងដើម្បីធានាការអភិវឌ្ឍន៍ដោយចីរភាពបរិស្ថានក្នុងការស្តារសេដ្ឋកិច្ចជាតិ ដោយមិនឱ្យបាត់បង់លំនឹងអេកូឡូស៊ីដែលជាគ្រោះមហន្តរាយដល់បរិស្ថានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាជន ។

ដើម្បីយល់ដឹងអំពីអត្ថប្រយោជន៍ និងដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាននាយកដ្ឋានសូមលើកឡើងដោយបំផុសសំនួរ និងចងក្រងជាចំលើយមួយចំនួនសំរាប់ការយល់ដឹងជាសាធារណៈដូចខាង ក្រោមនេះ:

សំនួរ: *តើអ្វីទៅការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ?*

ចម្លើយ: ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺជាដំណើរការមួយសំរាប់សិក្សាព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន ដែលអាចនឹងកើតមានឡើងពីគំរោងអភិវឌ្ឍន៍នានា ឬជាការសំរេចដ៏ជាក់លាក់មួយមុនពេលគំរោងអភិវឌ្ឍន៍ត្រូវបានអនុវត្តន៍ ដើម្បីធានាថារាល់ហេតុប៉ះពាល់អវិជ្ជមានរបស់គំរោងត្រូវបានរិះរកវិធានការទប់ស្កាត់ ឬការកាត់បន្ថយដល់កំរិតអប្បបរមា ហើយហេតុប៉ះពាល់វិជ្ជមានត្រូវបានលើកកំពស់ឱ្យដល់កំរិតអតិបរមា ព្រមទាំងមាន ផែនការគ្រប់គ្រងបរិស្ថានច្បាស់លាស់ទៀតផង ។

សំនួរ: *តើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តន៏លើគំរោងអភិវឌ្ឍន៏ណាខ្លះ? ទំហំគំរោងប៉ុណ្ណា? ហើយនរណាជាអ្នករៀបចំរបាយការណ៏វាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ?*

ចម្លើយ: យោងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានចែងថា: រាល់គំរោងអភិវឌ្ឍន៏ទាំងឡាយណាដែលបង្កឱ្យមានហេតុប៉ះពាល់ធ្ងន់ធ្ងរ ឬបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន សុខភាព និងសុខមាភាពសាធារណៈ( សង្គម) នោះម្ចាស់គំរោងត្រូវរៀបចំរបាយការណ៏វាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងអភិវឌ្ឍន៏របស់ខ្លួនដូចមានចែងក្នុងឧបសម្ពន្ឋ័នៃអនុក្រឹត្យនេះ ( ដូចជា: គំរោងអភិវឌ្ឍន៏ព្រលានយន្តហោះ ទំនប់វារីអគ្គិសនី ព្រៃសម្បទានការអភិវឌ្ឍន៏ទីក្រុង ។ល ។ និង ។ល ។) ដើម្បីធ្វើការសិក្សាព្យាករណ៏ និងកំណត់ទំហំនៃការប៉ះពាល់ទាំងនោះ រួចលើកវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានទាំងនោះឱ្យដល់កំរិតអប្បបរមាដែលអាចទទួលយកបាន ។



**ឯកសារនានាដែលក្រសួងបរិស្ថាននិង នាយកដ្ឋាន EIA សំរេចបានក្នុងការធានាគតិយុត្តិក្នុងការអនុវត្តន៏ការវាយតំលៃហេតុ ប៉ះពាល់បរិស្ថាន**

សំនួរ: *តើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានសារៈប្រយោជន៍អ្វីខ្លះសំរាប់សង្គម និងបរិស្ថាន?*

ចម្លើយ: *សំរាប់សង្គម:* ការពារសុខភាព និងសុខមាលភាពសាធារណៈ (ដូចជា: ជំងឺការបំពុលភាពកខ្វក់ និងដើម្បីរក្សានូវភាពសុខដុមរម្យនានៃសង្គម និងធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ល។

*សំរាប់បរិស្ថាន:* រក្សានូវធនធានធម្មជាតិដ៏មានតំលៃ **ដូចជា: ព្រៃឈើ [illegible]** **គុណភាពទឹក-ដី-ខ្យល់ ពូជសត្វកំរ និងជីវៈ [illegible]**



**មន្ត្រីបរិស្ថាន ចុះសិក្សាហេតុប៉ះពាល់បរិស្ថាន**

**នៅសណ្ឋាគារសុខា ក្រុងព្រះសីហនុ**

គួរចងចាំថា "បរិស្ថាន និង សង្គម" វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតមិនអាចខ្វះបាន ព្រោះមនុស្សយើងដើម្បីសុខភាព និងភាពសុខដុមរម្យនា គឺត្រូវការខ្យល់បរិសុទ្ធសំរាប់ដកដង្ហើម ទឹកស្អាត និងអាហារប្រកបដោយអនាម័យសំរាប់បរិភោគ និងទ្រទ្រង់រាងកាយ ហើយយើងចង់រស់នៅក្នុងលក្ខខណ្ឌបរិយាកាសល្អដោយមិនចង់ជួបប្រទះនូវគ្រោះមហន្តរាយនៃធម្មជាតិយាយីគួរឱ្យតក់ស្លុត នោះឡើយ ។

ដូច្នេះ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពិតជាមានសារៈប្រយោជន៍សំរាប់ជីវិតយើងគ្រប់រូបរស់នៅលើផែនដីនេះ ហើយវាជាឧបករណ៍គតិយុត្តិមួយរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងបរិស្ថានក្នុងការទប់ស្កាត់បទល្មើសនានាដែលអាចនាំដល់គ្រោះមហន្តរាយធនធានធម្មជាតិ និងធនធានសេដ្ឋកិច្ចសង្គមនានាក្នុងការអភិវឌ្ឍន៍ ។

***អត្ថបទ: នាយកដ្ឋាន អង្កេត ពិនិត្យ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន***

នាទីចំណេះដឹង បញ្ហាសង្គម

# ច្បាប់ធម្មជាតិ និងជីវិតសត្វលោក

## I. សេចក្ដីផ្ដើម:

បច្ចុប្បន្ន ទោះបីធម្មជាតិពុំបានផ្ដល់នូវភោគទ្រព្យគ្រប់បែបយ៉ាងជាសម្ភារៈសំរាប់ទ្រទ្រង់ ការរស់នៅរបស់មនុស្ស ហើយមនុស្សត្រូវតែធ្វើពលកម្មផលិតស្បៀងអាហារ និងផលិតទ្រព្យសម្ភារៈគ្រប់បែបយ៉ាងដើម្បីទ្រទ្រង់ការរស់នៅរបស់ខ្លួន ព្រមទាំងដើម្បីអភិវឌ្ឍន៍សង្គមយ៉ាងណាក៏ដោយ តែធម្មជាតិបានផ្ដល់នូវភោគទ្រព្យយ៉ាងសំបូរបែបទាំងលើដី ក្នុងដីក្រោមដី ក្នុងទឹក ទាំងទឹកសាប និងទឹកប្រៃ ព្រមទាំងក្នុងលំហអាកាសផងដែរ ។ ក្នុងនោះអ្វីដែលយើងឃើញមិនអាចបដិសេធបាននោះ គឺធនធានជីវៈចំរុះគ្រប់ប្រភេទដែលជាវត្ថុធាតុដើម និងជាស្បៀងអាហារ ។

ក្នុងការធ្វើផលិតកម្ម មនុស្សមិនអាចធ្វើសកម្មភាពតាមគំនិតអត្តនោម័តដោយធ្វើរំលងឬបំពានច្បាប់ធម្មជាតិបានឡើយ ។ បើមនុស្សមិនបានគោរពម៉ឺងម៉ាត់តាមគោលការណ៍នេះទេ នោះសកម្មភាពរបស់មនុស្សនឹងទទួលបរាជ័យ ។

ដូច្នេះសួរថា តើច្បាប់ធម្មជាតិ និងជីវិតសត្វលោកមានអន្តរកម្មគ្នាយ៉ាងណា?



**ជុំវិញផ្ទះប្រជាកសិករសាមញ្ញនេះ យើងសង្កេតឃើញមានដើមត្នោតដែលដុះខ្ពស់សន្ធឹមជាច្រើនដើម។ ទោះបីដើមត្នោតទាំងនោះវាមិនបានផ្ដល់ស្ករដោយផ្ទាល់មកប្រជាកសិករ តែវាបានផ្ដល់នូវផ្លែនិងផ្កាដែលមានសារជាតិផ្អែម។ យ៉ាងណាមិញភោគផលស្រូវដែលប្រជាកសិករកំពុងបោកបែន នេះគឺមានប្រភពមកពីបរិស្ថានធម្មជាតិដែលសមស្របសំរាប់ទឹកដីនៅក្នុងភូមិសាស្ត្រនេះ។**

# II. ច្បាប់ធម្មជាតិ និងជីវិតសត្វលោក

## ក. ច្បាប់ធម្មជាតិ

ក្នុងការគ្រប់គ្រងសង្គម មនុស្សបានបង្កើតច្បាប់ បានបង្កើតបញ្ញត្តិនានា បានកសាងបែបបទជាប្រពៃណី សីលធម៌ **ទំនៀមទម្លាប់...ដើម្បីរៀបចំ** និងដឹកនាំសង្គមអោយមានសណ្តាប់ធ្នាប់ ។ ទោះបីប្រជាជាតិនិមួយៗមានការគោរព **ប្រពៃណី [illegible] និយម**ទំនៀមទម្លាប់ខុសគ្នាដែលជាអត្តសញ្ញាណជាតិយ៉ាងណាក៏ដោយ តែការគ្រប់គ្រងសង្គមដោយ **បញ្ញត្តិ [illegible] ច្បាប់ដើម្បីធានាសណ្តាប់ធ្នាប់សង្គម** គឺជាលក្ខណៈសកលសំរាប់គ្រប់ប្រទេសទាំងអស់លើ **សកល [illegible] ជ្រាលជ្រៅជាងគេ គឺច្បាប់រដ្ឋធម្មនុញ្ញ** ។

**[illegible] គ្រប់រូបត្រូវតែអនុវត្តន៍តាម** ។ នៅប្រទេសដែលអនុវត្តន៍ **[illegible] ប្រជាពលរដ្ឋគ្រប់រូបស្ថិតនៅ**ក្រោមសំណាញ់ច្បាប់មិនមានការលើកលែងឡើយ ហើយអ្នក **ប្រព្រឹត្តល្មើសត្រូវទទួល**ទោសតាមកំរិតនៃបទល្មើសរបស់ខ្លួនដែលមានចែងក្នុងច្បាប់ ដោយមានតុលាការ រដ្ឋអំណាច និង គុកជាឧបករណ៍អនុវត្តន៍ច្បាប់ ។

*ចំណែកច្បាប់ធម្មជាតិវិញយ៉ាងណា?*

ច្បាប់ធម្មជាតិ គឺជាដំណើរប្រព្រឹត្តសារចុះសារឡើងរបស់ធម្មជាតិ វាមិនចំណុះនឹងឆន្ទៈរបស់មនុស្សឡើយ ។ ច្បាប់ធម្មជាតិអាចហៅម្យ៉ាងទៀតថាក្រឹត្យក្រមធម្មជាតិ ។

ឧទាហរណ៍: -ផែនដីមានរាងមូលហើយវាវិលជុំវិញព្រះអាទិត្យ

-ទឹកហូរពីលើចុះក្រោម ។

............................................

ច្បាប់ធម្មជាតិពុំមានឧបករណ៍សំរាប់ត្រួតពិនិត្យ និងតាមដានការអនុវត្តន៍ដូចច្បាប់សង្គមឡើយ ។ ប៉ុន្តែបើមនុស្សមិនគោរពច្បាប់ធម្មជាតិ ឬមិនអនុវត្តន៍តាមក្រឹត្យក្រមធម្មជាតិ មនុស្សមិនអាចធ្វើអ្វីសំរេចបានជោគជ័យឡើយ ។ ការមិនទទួលបានជោគជ័យនេះ គឺជាការផ្តន្ទាទោសរបស់ធម្មជាតិទៅលើអ្នកបំពានច្បាប់ធម្មជាតិ ។

## ខ. អន្តរកម្មរវាងច្បាប់ធម្មជាតិ និងជីវិតសត្វលោក:

ឧទាហរណ៍យ៉ាងសាមញ្ញមួយអំពីការដាំស្រូវ ។ នៅព្រះរាជាណាចក្រកម្ពុជាមានពូជស្រូវជាច្រើនប្រភេទ ។ ក្នុងនោះក៏មានស្រូវដែលត្រូវដាំដុះនៅរដូវវស្សា នៅរដូវប្រាំង នៅតំបន់ភ្នំ និងនៅតំបន់វាលទំនាបជុំវិញបឹងទន្លេសាប ។ ប្រាកដណាស់ បើយើងយកពូជស្រូវត្រូវដាំដុះនៅរដូវវស្សាទៅដាំនៅរដូវប្រាំង នោះយើងប្រាកដជាគ្មានទឹកគ្រប់គ្រាន់សំរាប់ស្រោចស្រពវាឡើយ ។ តែបើមានទឹកក៏ត្រូវចំណាយទុននិងពលកម្មយ៉ាងច្រើន ព្រោះវាមានរយៈពេល5 ឬ6ខែ

ទើបអាចប្រមូលផលបាន ។ យ៉ាងណាមិញ បើយើងយកស្រូវតំបន់ភ្នំទៅសាបព្រោះនៅតំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាបនោះ ប្រាកដជាវាត្រូវវិលល្វយអស់ ព្រោះវាលូតមិនទាន់ការកើនឡើងកំពស់ទឹកដែលមានភាពគំហុក។ នៅតំបន់នោះមាន តែពូជស្រូវឡើងទឹកទេ ទើបអាចលូតលាស់បាន ។

ការអនុវត្តន៏បានត្រឹមត្រូវការដាំដុះស្រូវតាមលក្ខណៈធម្មជាតិដែលបានរៀបរាប់ខាងលើ បានឆ្លុះបញ្ចាំងថា បើមនុស្សមិនអនុវត្តន៏តាមច្បាប់ធម្មជាតិទេនោះ ទោះបីការចំណាយពលកម្ម និងចំណាយធនធានអស់ច្រើនលើសលប់ ប៉ុណ្ណាក៏មិនបានទទួលផលអ្វីដែរ។

និយាយយ៉ាងដូច្នេះ មិនមែនបានន័យថាមនុស្សត្រូវទទួលយកគ្រប់លក្ខខ័ណ្ឌដែលមានស្រាប់ក្នុងធម្មជាតិទាំងអស់នោះទេ មនុស្សត្រូវតែចេះកែឆ្នៃធម្មជាតិទៅតាមលក្ខណៈវិទ្យាសាស្ត្រផងដែរ តែត្រូវរក្សាក្រឹត្យក្រមឬច្បាប់ធម្មជាតិជានិច្ច ។ សព្វថ្ងៃដោយសារវិទ្យាសាស្ត្ររីកចំរើនមនុស្សបានយល់ពីច្បាប់ធម្មជាតិពហុសណ្ឋានហើយស្ទើរតែគ្មានអ្វីដែលស្ថិតនៅជា អាទិកំបាំងដែលមនុស្សមិនអាចយល់បាននោះឡើយ ។




*ធម្មជាតិជាអ្នកបង្កើតភ្លៀង ។ ភ្លៀងវាមានដំណើរកើតឡើងរបស់វា ហើយវាក៏មានប្រភពបង្កើតវាផងដែរ ។ បើមនុស្សបំផ្លាញបរិស្ថានធម្មជាតិ ដែលជាប្រភពបង្កើតអោយមានភ្លៀង នោះវានាំអោយកើតមានភាពរាំងស្ងួត ឬក៏គ្រោះទឹកជំនន់ដែលជះឥទ្ធិពលជាអវិជ្ជមានដល់ការលូតលាស់ជីវៈចំរុះ និងការបង្កបង្កើនផលរបស់ប្រជាកសិករ ។*

ទឹកប្រាកដជាហូរពីទីខ្ពស់មកទីទាប ប៉ុន្តែមនុស្សអាចធ្វើអោយទឹកហូរពីទីទាបទៅទីខ្ពស់បាន ដោយមនុស្សប្រើបច្ចេកទេសវិទ្យាសាស្ត្រតាមច្បាប់ធម្មជាតិ ។ បច្ចុប្បន្នទីក្រុងមានទឹកម៉ាស៊ីនប្រើប្រាស់ ដោយសារការធ្វើសំយោគរវាងទ្រឹស្តីវិទ្យាសាស្ត្រជាមួយក្រឹត្យក្រមធម្មជាតិ ។

ទាំងនេះគឺជាឧទាហរណ៍បញ្ជាក់ពីអន្តរកម្មរវាងច្បាប់ធម្មជាតិជាមួយនឹងជីវិតសត្វលោក ហើយមនុស្សគ្រប់រូបត្រូវយល់ថា អ្វីៗដែលធម្មជាតិបានបង្កើតឡើងវាសុទ្ធតែមានប្រយោជន៍មានតួនាទីបំពេញអោយគ្នាទៅវិញទៅមកសំរាប់

វក្យាលនឹងបរិស្ថានធម្មជាតិ ។ យ៉ាងដូច្នេះហើយបានជាអ្នកបរិស្ថានអះអាងថា ធម្មជាតិបានបង្កើតសត្វខ្លា ហើយតម្រូវអោយខ្លាស៊ីសត្វម្រឹគជាអាហារ ព្រោះប្រសិនបើគ្មានសត្វខ្លាសំរាប់ស៊ីកំចាត់សត្វម្រឹគដែលជាចំនួនលើសទេនោះ នោះសត្វម្រឹគម្រឹគានឹងកើនចំនួនហួសហេតុ ហើយវាស៊ីខ្ចេចរុក្ខជាតិមិនអាចអោយវាដុះលូតលាស់បានឡើយ ។ នៅមានឧទាហរណ៍ច្រើនជាងនេះទៀតដើម្បីអះអាងបញ្ជាក់បញ្ហានេះ ។



*ដោយសារការរីកចំរើននៃវិទ្យាសាស្ត្របច្ចេកទេស នាំអោយសង្គមមានការអភិវឌ្ឍន៍រីកចំរើនលើគ្រប់វិស័យ ។ នៅប្រទេសជឿនលឿន ការធ្វើកសិកម្មបានជំនួសកំលាំងសត្វនិងកំលាំងមនុស្សដោយប្រើគ្រឿងយន្ត ។ ដូច្នេះការភ្ជួររាស់ដោយមនុស្សដើរពីក្រោយនង្គ័លឬរនាស់ត្រូវជំនួសដោយគោយន្ត ។ នៅកម្ពុជាទោះបីជាទូទៅប្រជាកសិករនៅបន្តអនុវត្តន៍កសិកម្មបែប ប្រពៃណី ក៏មានប្រើប្រាស់គោយន្តនៅកន្លែងខ្លះផងដែរ ។*

ដើម្បីរស់និងបន្តពូជពង្ស មនុស្សនិងសត្វត្រូវទទួលយកលក្ខខ័ណ្ឌធម្មជាតិជាប្រភពជីវិត និងជាប្រភពចំណីអាហាររបស់ខ្លួន ។ នៅកម្ពុជាលក្ខខ័ណ្ឌធម្មជាតិ តម្រូវអោយខ្មែរហូបបាយ ព្រោះកម្ពុជាមិនអាចដាំស្រូវភោជសាលី (Blé) ដូចនៅអឺរ៉ុបឡើយ ។ ដោយសារលក្ខខ័ណ្ឌធម្មជាតិនេះដែរ មនុស្សជាសត្វលោកដែលខ្លាំងជាងគេ ហើយបានទទួលឋានៈដ៏ពិសិដ្ឋធ្វើជាស្តេចនៃចក្រវាឡ ។ តែក្នុងឋានៈដ៏ពិសិដ្ឋនេះ បើមនុស្សបំផ្លាញបរិស្ថានធម្មជាតិឬធ្វើ អោយបរិស្ថានធម្មជាតិបាត់លក្ខណៈដើម មនុស្សមិនអាចបន្តអត្ថិភាពលើភពផែនដីនេះតទៅទៀតបានឡើយ ។

សព្វថ្ងៃនេះ បរិស្ថានធម្មជាតិបានទទួលរងការធ្វើអាជីវកម្មហួសហេតុ ដែលបណ្តាលមកពីលទ្ធភាពផ្តល់របស់ធម្មជាតិមានកំរិត តែសេចក្តីត្រូវការរបស់មនុស្សគ្មានព្រំដែន ហើយចំនួនមនុស្សកើនឡើងឥតឈប់ឈរ ចំណែកភពផែនដីដែលមនុស្សលោករស់នៅមានទំហំដដែល ។

ដូច្នេះជីវិតសត្វលោករាប់បញ្ចូលទាំងជីវិតមនុស្សផង ដើម្បីបន្តអត្ថិភាពលើភពផែនដី ត្រូវមានលក្ខខ័ណ្ឌធម្មជាតិចាំបាច់ដែលធម្មជាតិបានបង្កើតមកមិនអាចខ្វះបាន ហើយមនុស្សត្រូវការពារបរិស្ថានភពផែនដីឱ្យមាននិរន្តរភាព ។

តាមការនិទានត។ គ្នារបស់ពុទ្ធសាសនិកជនបានអោយដឹងថា ដល់គំរប់5000ព្រះវស្សានៃពុទ្ធសករាជ ភពផែនដីដែលយើងកំពុងរស់នៅនឹងកើតមានបាតុភូតភ្លើងឆេះកប្ប ។ បើបាតុភូតនេះកើតមានឡើងពិតមែន តើអាចមានជីវិតសត្វលោកណាមួយអាចបន្តរស់នៅឬទេ? ។

សេចក្តីដែលបានរៀបរាប់ពីអន្តរកម្មរវាងច្បាប់ធម្មជាតិនិងជីវិតសត្វលោក យើងអាចសង្ខេបខ្លីគឺៈ អ្វី។ដែលមាននៅលើភពផែនដីទាំងរបស់មានជីវិត និងឥតជីវិត គឺធម្មជាតិជាអ្នកបង្កើតឡើង ហើយអ្វី។ទាំងនោះធ្វើចលនាតាមច្បាប់ធម្មជាតិ វាមិនចំណុះឆន្ទៈ របស់មនុស្សឡើយ ។ សង្គមមនុស្សអាចអភិវឌ្ឍន៍និងរីកចំរើនដូចសព្វថ្ងៃ គឺដោយសារមនុស្សបានយល់ដឹងពីក្រឹត្យក្រមធម្មជាតិ ហើយមនុស្សបានយកការយល់ដឹងទាំងនោះទៅកែឆ្នៃធម្មជាតិ ផលិតជាទ្រព្យសម្ភារៈបំរើអោយសង្គម ដោយគោរពយ៉ាងម៉ឹងម៉ាត់ច្បាប់ធម្មជាតិ ។

## III<u>**សន្និដ្ឋានៈ**</u>

ធម្មជាតិជាអ្នកបង្កើតសត្វលោក ហើយធម្មជាតិបានផ្តល់នូវធនធានគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមមនុស្ស ។ ធម្មជាតិមិនដែលទាមទារភាគហ៊ុន ផលកំរៃឬផលប្រយោជន៍អ្វីពីមនុស្សឡើយ ។ ធម្មជាតិបានខ្សិបដាក់ត្រចៀកមនុស្សគ្រប់រូបអោយក្រោកឡើង ហើយពួតដៃគ្នាជួយថែរក្សាភោគទ្រព្យដែលជាបរិស្ថានធម្មជាតិអោយមានដំណើរប្រព្រឹត្តទៅដោយនិរន្តរភាពក្នុងការធ្វើអាជីវកម្ម ។ បើមិនដូច្នោះទេ ធម្មជាតិនឹងផន្ទាទោសមនុស្សដោយគ្រោះអត់ឃ្លាន គ្រោះទុរភិក្សសេចក្តីឈឺចាប់ នឹងទុក្ខវេទនា រាប់រយរាប់ម៉ឺនជំពូក ដែលចុងក្រោយបំផុត ពូជមនុស្សត្រូវតែវិនាសផុតពូជពីភពផែនដី ។

ធម្មជាតិមានធម៌មេត្តា មានការអាណិតអាសូរដល់មនុស្សលោកណាស់ មានតែមនុស្សទេដែលធ្វើបាបមនុស្សដូចគ្នា ។

ភពផែនដីមានតែមួយ ហើយតែមួយគត់ ។ វាជាផ្ទះរបស់យើង ទីជំរកយើង យើងត្រូវការពារវាជានិច្ច ។

រៀបរៀងដោយៈ **នុប_និមល**

# ការស្វែងយល់ពីផលប៉ះពាល់របស់ផ្សែងទៅលើសុខភាព និងបរិស្ថាន

## I. តើអ្វីទៅដែលហៅថាផ្សែង?

**នៅក្នុង**បរិបទបរិស្ថាន យើងបានឱ្យនិយមន័យនៃពាក្យផ្សែងថា: [illegible] **ឧស្ម័នរួម**ផ្សំជាមួយនឹងកំទេចម្រែងភ្លើង ចំហាយ [illegible] **(ភាគល្អិត)** ដូចជាសារធាតុសរីរាង្គ និង [illegible] **ឬអង្គធាតុសមាសដែលហុយចេញ** [illegible] **ណោះ**ធាតុក្តៅ ឬប្រតិកម្មគីមី ។ [illegible] **ជាង២មីក្រុង** ហើយវាអាចជាសមាសធាតុស៊ុលស្យូម *ក្លរអរ អាលុយមីញ៉ូម* សំណ អាស៊ីតបាស និង សមាសធាតុគីមីផ្សេងទៀត ដូចជាផេណុលជាដើម ។

## II. សមាសធាតុនៃផ្សែង

យើងបានដឹងថា ផ្សែងបានធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិ ។ ផលប៉ះពាល់នេះ គឺវាអាស្រ័យទៅលើសមាសធាតុផ្សំរបស់ផ្សែង (ធាតុផ្សំរបស់ផ្សែង) ។ នេះមានន័យថា បើកាលណាធាតុផ្សំរបស់ផ្សែង មានផ្ទុកទៅដោយសារធាតុពុល (សារធាតុគីមីពុល ឬតុកសិច) ឬឧស្ម័នអាស៊ីត នោះកិរិតនៃផលប៉ះពាល់មកលើសុខភាពមនុស្ស សត្វ និងរុក្ខជាតិ គឺមានសភាពធ្ងន់ធ្ងរទៅតាមប្រភេទ និងកិរិតកំហាប់ នៃសារធាតុពុលទាំងនោះ ។

ប្រភេទសារធាតុពុល ដែលគេសង្កេតឃើញមាននៅក្នុងផ្សែងរួមមាន:

- ក្រុមឧស្ម័នកាបូនិក ($CO_x$) **រួមមានឧស្ម័នកាបូនិក ($CO_2$)** និងឧស្ម័នកាបូនម៉ូណូអុកស៊ីត ($CO$)
- ក្រុមឧស្ម័នស្ពាន់ធ័រ ($SO_x$) រួមមានឧស្ម័នស៊ុលហ្វួរី ($SO_2$) និងឧស្ម័នស៊ុលហ្វួរិក ($S_2O_3$)
- ក្រុមឧស្ម័នអាសូតអុកស៊ីត ($NO_x$) រួមមានឧស្ម័ននីត្រី (ឬ អាសូតម៉ូណូអុកស៊ីត - $NO$) ឧស្ម័ននីទ្រិក (ឬ អាសូតឌីអុកស៊ីត - $NO_2$) និង ឧស្ម័នឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) ។
- ក្រុមចុណ្ណភាគលោហៈ រួមមានសំណ ($Pb$) មង់ហ្គាណែស ($Mn$) ។ល។ក្រុមសារធាតុសរីរាង្គ រួមមានសារធាតុឌីអុកស៊ីន, ហ្វូរ៉ាន់, .... ។ល។ ក្រុមសារធាតុអសរីរាង្គ រួមមានកំទេចម្រែងភ្លើង, លំអងធ្យូង, លំអងធូលី ... ។ល។
- និងក្រុមសារធាតុផ្សេងៗទៀត ដូចជាសារធាតុនីកូទីនជាដើម (មាននៅក្នុងផ្សែងបារី) ។ល។

## III. ប្រភពបញ្ចេញផ្សែង

ប្រភពដែលបញ្ចេញផ្សែងមានច្រើនប្រភេទ ដូចជាការដុតសំរាមនៅតាមផ្ទះ និងទីលានចាក់សំរាម ការចំអិនម្ហូបអាហារតាមផ្ទះ ការដុតភាពព្រៃធ្វើស្រែចំការ ដំណើរចំហេះនៅតាមរោងចក្រ យានយន្ត។ល។ តាមការកត់សំគាល់ គេអាចបែងចែកប្រភពដែលបញ្ចេញផ្សែងសំខាន់ៗ បានដូចខាងក្រោម:

- <u>ផ្សែងដែលបញ្ចេញពីលំនៅដ្ឋាននិងការដុតសំណល់កសិកម្ម</u> ជាប្រភេទផ្សែងដែលកើតឡើងដោយការចំអិនចំណីអាហារ ដូចជាការដុតអុស ធ្យូង និងឧស្ម័នមេតាន និងការដុតសំណល់កសិកម្ម (ភាគច្រើនជាប្រភេទរុក្ខជាតិ, មិនរាប់ បញ្ចូលផលិតផលឧស្សាហកម្មដែលប្រើសំរាប់វិស័យកសិកម្មទេ) ដែលធាតុផ្សំរបស់វាសំបូរទៅដោយឧស្ម័នកាបូនិក ចំហាយ ទឹក និងកំទេចម្រែងភ្លើង ។
- <u>ផ្សែងដែលបញ្ចេញពីរោងឧស្សាហកម្ម</u>: ជាប្រភេទផ្សែងដែលបញ្ចេញពីបំពង់ផ្សែងរោងចក្រនានា ដូចជារោងចក្រថាមពល **អគ្គិសនី រោងចក្រ** [illegible] សារធាតុអ៊ីដ្រូកាប៊ូ និងចុណ្ណភាគ នានា ។



*ផ្សែងដែលបញ្ចេញពីរោងចក្រ-សហគ្រាសសំបូរទៅដោយជាតិពុលគ្រប់ប្រភេទ ។ រូបភាពនៃរោងចក្រនៅប្រទេសអាមេរិក ។*

❖ <u>ផ្សែងដែលបញ្ចេញពីយានយន្តគ្រប់ប្រភេទ</u>: គឺជាប្រភេទផ្សែងដែលបញ្ចេញចោលពីយានយន្តនានា ដូចជាម៉ូតូ ឡាន កប៉ាល់យន្តហោះ និងម៉ាស៊ីនភ្លើងតូច-ធំប្រចាំគ្រួសារ ឬសហគ្រាស ដែលមានផ្ទុកសារធាតុពុល ស្រដៀងគ្នាទៅនឹងផ្សែង ដែលបញ្ចេញពីរោងឧស្សាហកម្មដែលដើរដោយថាមពលឥន្ធនៈហ្វូស៊ីល (ប្រេង)។ បរិមាណធាតុពុល របស់ឧស្ម័នកាបូនម៉ូណូអុកស៊ីត ឧស្ម័នស្ពាន់ធ័រ ឧស្ម័នអាសូតសារធាតុអ៊ីដ្រូកាបួ និងចុណ្ណភាគនានា ដែលអាចមាននៅក្នុងផ្សែងប្រភេទនេះ គឺសមាមាត្រទៅនឹងបរិមាណនៃសារធាតុកាបូន ស្ពាន់ធ័រអាសូត និងលោហៈ ដែលមានស្រាប់នៅក្នុងប្រេងឥន្ធនៈ លើកលែងតែឧស្ម័នកាបូនម៉ូណូអុកស៊ីតមួយគត់ ដែលបរិមាណរបស់វាអាស្រ័យទៅលើចំហេះសព្វ ឬមិនសព្វរបស់ឥន្ធនៈ។ នេះមានន័យថា បើកាលណាប្រេងឆេះសព្វល្អ នោះបរិមាណឧស្ម័នកាបូនម៉ូណូអុកស៊ីត ដែលបញ្ចេញមកមានចំនួនតិច។ ផ្ទុយទៅវិញ បើប្រេងឆេះមិនសព្វល្អទេ នោះបរិមាណឧស្ម័នកាបូនម៉ូណូអុកស៊ីត ដែលបញ្ចេញមកនឹងមានបរិមាណច្រើន ។

❖ <u>ផ្សែងដែលបញ្ចេញពីការដុតសំរាម</u>: (នៅទីវាលចាក់សំរាម និងឡដុតសំរាម)។ គេពិបាកនឹងធ្វើការសន្និដ្ឋានអំពី បរិមាណជាតិពុលឱ្យបានជាក់លាក់ ដែលមាននៅក្នុងកំហាប់ផ្សែងដែលជាផលនៃការដុតសំរាមនៅតាមទីលានចាក់សំរាម ឬក៏ឡដុតសំរាម។ មូលហេតុដែលធ្វើឱ្យគេពិបាកប៉ាន់ប្រមាណពីប្រភេទ និងបរិមាណជាតិពុល ដែលមាននៅក្នុងផ្សែងប្រភេទនេះ ដោយសារសំរាម គឺជាបណ្ដុំនៃសំណល់ទាំងឡាយ ចាប់តាំងពីសំណល់ពីផ្ទះបាយ សំណល់មន្ទីរពេទ្យ សំណល់ពីរោងចក្រ សំណល់ធម្មជាតិ/រុក្ខជាតិ ។ល។ សំណល់ទាំងនេះក៏មានផ្ទុកទៅដោយសារធាតុពុលផ្សេងៗផងដែរ ដូចជាសំណល់ថ្នាំសំលាប់សត្វល្អិត ថ្នាំលាប ថ្នាំពេទ្យ កំទេចកណាត់ដែលជ្រលក់ទឹកពណ៌គីមី ។ល។ និង ។ល។ ដូចនេះ កំរិតជាតិពុលមាននៅក្នុងផ្សែង ដែលជាផលនៃការដុតសំរាម គឺមានច្រើនប្រភេទ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញមានសារធាតុពុលមួយចំនួន បានកកើតឡើងពីការដុតសារធាតុនានា ទោះជាដុតនៅតាមទីវាល ឬនៅតាមឡដុតសំរាម ដែលសារធាតុនោះមានឈ្មោះថា ឌីអុកស៊ីន និងហ្វូរ៉ាន់ ដែលជាសារធាតុពុលមិនបំបែកធាតុ និងមានកំរិតពុលខ្ពស់បំផុត។ សារធាតុពុលនេះ កើតឡើងពីការដុតសំណល់ប្លាស្ទិក ខ្សែភ្លើង ដែលផ្សំឡើងពីសមាសធាតុក្លរ។

❖ <u>ផ្សែងបារី</u>: ជាផ្សែងដែលកើតមានឡើងដោយសារការជក់បារី។ ផ្សែងនេះមានផ្ទុកទៅដោយសារធាតុនីកូទីន។

❖ <u>ក្រុមផ្សែងផ្សេងៗទៀត</u>: ដូចជាផ្សែងពីបន្ទុះភ្នំភ្លើង ផ្សែងពីការបង្ហោះកាំជ្រួចអវកាស ផ្សែងពីការប្រើប្រាស់គ្រឿងសព្វាវុធ ។ល។ ផ្សែងប្រភេទនេះ នឹងមិនយកមកធ្វើការបកស្រាយនៅក្នុងអត្ថបទនេះទេ ។

## IV. ឥទ្ធិពលនៃផ្សែងទៅលើសុខភាព

យើងដឹងហើយថាមនុស្ស និងសត្វ សុទ្ធតែត្រូវការខ្យល់អុកស៊ីហ្សែន ដើម្បីដកដង្ហើម ហើយបញ្ចេញមកវិញនូវឧស្ម័នកាបូនិក និងចំហាយទឹក ដែលសរីរាង្គយើងមិនត្រូវការ។ ដូចគ្នានេះដែរ រាល់ចំហេះទាំងឡាយ ក៏សុទ្ធតែត្រូវការខ្យល់អុកស៊ីហ្សែន ដើម្បីទ្រទ្រង់ចំហេះរបស់វា និងបញ្ចេញមកវិញនូវផ្សែង (ភាគច្រើនជាឧស្ម័នកាបូនិក) ចំហាយទឹក និងផេះ។ ដូចនេះយើងអាចនិយាយបានថាផ្សែងមានការប៉ះពាល់ទៅលើសុខភាពរបស់មនុស្ស និងសត្វ ពីព្រោះថាផ្សែងនេះ សំបូរទៅដោយឧស្ម័នកាបូនិក ដែលជាឧស្ម័នមួយមិនទ្រទ្រង់ដំណកដង្ហើម និងចំហេះ។ លើសពីនេះទៅទៀត យើងនឹងជួបប្រទះនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រសិនបើនៅក្នុងផ្សែនោះសំបូរទៅដោយសារធាតុពុលនានា ដូចដែលបានរៀបរាប់ខាងលើ។ សារធាតុពុលទាំងនេះ នឹងបង្ករឱ្យយើងជួបប្រទះនូវជំងឺមួយចំនួនដូចខាង ក្រោម:

❖ ក្រុមឧស្ម័នកាបូនិក ($CO_x$)។ ឧស្ម័នកាបូនិក ជាឧស្ម័នដែលមិនទ្រទ្រង់ដល់ដំណេកដង្ហើមទេ ប៉ុន្តែវាក៏មិនធ្វើឱ្យប៉ះពាល់ដល់សុខភាពដែរ។ ផ្ទុយទៅវិញ ឧស្ម័នកាបូនម៉ូណូអុកស៊ីត គឺមានគ្រោះថ្នាក់ខ្លាំងណាស់ដល់សុខភាព នៅពេលដែលយើងស្រូបយកវាចូលទៅក្នុងសួត។ ឧស្ម័ននេះនឹងចាប់យកគ្រាប់ឈាមក្រហម ធ្វើឱ្យគ្រាប់ឈាមក្រហម មិនអាចដឹកជញ្ជូនខ្យល់អុកស៊ីហ្សែនទៅចិញ្ចឹមដល់រាងកាយយើងបាន។ បរិមាណឧស្ម័នកាបូនម៉ូណូអុកស៊ិត ច្រើនកាលណានៅក្នុងខ្លួន នោះវានឹងធ្វើឱ្យយើងមានអាការៈថប់ដង្ហើម និងអាចបណ្ដាលឱ្យស្លាប់បាន ។

❖ ក្រុមឧស្ម័នស្ពាន់ធ័រ ($SO_x$)។ ឧស្ម័នស្ពាន់ធ័រអុកស៊ីត រួមចំណែកបង្កឱ្យមានជំងឺរលាកផ្លូវដង្ហើម ជាពិសេសចំពោះកុមារ និងមនុស្សចាស់ ហើយវាក៏ធ្វើជំងឺបេះដូងដែលមានស្រាប់ កាន់តែមានសភាពធ្ងន់ធ្ងរឡើង និងធ្វើឱ្យមានជំងឺសួត ។

❖ ក្រុមឧស្ម័នអាសូតអុកស៊ីត ($NO_x$)។ ឧស្ម័នអាសូតអុកស៊ីតនឹងបង្ករឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងមកលើ សុខភាពរបស់មនុស្សជាពិសេសប៉ះពាល់ដល់ប្រព័ន្ធដកដង្ហើម (ធ្វើឱ្យមានជំងឺសួត) ដោយវាបានបំផ្លាញកោសិកាសួត ធ្វើឱ្យសួតដំណើការមិនប្រក្រតី និងអាចបណ្ដាលឱ្យស្លាប់បាន ។

❖ ក្រុមចុណ្ណភាគលោហៈ។ ចុណ្ណភាគដែលគេសំគាល់ឃើញមានការប៉ះពាល់ខ្លាំងដល់សុខភាព គឺចុណ្ណភាគសំណ ដែលជាទូទៅត្រូវបានបញ្ចេញចោលតាមផ្សែងពីគ្រឿងម៉ាស៊ីន ដែលប្រើឥន្ធនៈមានសំណ។ ចុណ្ណភាគសំណ នឹងធ្វើឱ្យខូចខាតដល់ដំរងនោម ថ្លើម ប្រព័ន្ធខួរក្បាល និងសរសៃប្រសាទ និងខូចសរីរាង្គផ្សេងៗនៅក្នុងខ្លួនយើង។ **វាក៏អាចធ្វើឱ្យមានជំងឺពុកឆ្អឹង** និងបញ្ហាបន្តពូជ។ លើសពីនេះទៅ [illegible] **មានជំងឺ**លើសឈាម ជំងឺបេះដូង (ជាពិសេសសំរាប់ [illegible] **ឱ្យ**ប្រែប្រួលស្មារតីចុះខ្សោយប្រាជ្ញា និង [illegible]

[illegible] **និងហ្វូរ៉ាន់** គឺជា [illegible] **ធាតុ និង** [illegible] **ឱ្យមាន** **គ្រោះថ្នាក់ដល់សុខភាព ដូចជា: ធ្វើឱ្យងាប់ និងថយចុះនូវជាលិកា**ស្បែក, ធ្វើឱ្យប្រែប្រួលតួនាទីរបស់ថ្លើម និងសកម្មភាពអង់ស៊ីមរបស់ថ្លើម, ភាពខ្សោយទូទៅ ដូចជាថយទំងន់ ហេវហត់អស់កំលាំង, ប្រែប្រួលនូវប្រតិកម្មមេតាបូលីសរបស់ខ្លាញ់, ធ្វើឱ្យធ្លាក់ចុះនូវប្រព័ន្ធការពារជំងឺ, ខូចប្រព័ន្ធប្រសាទ, ចុះខ្សោយប្រាជ្ញាស្មារតី, ប្រែប្រួលនូវបុគ្គលិកលក្ខណៈ ដូចជាឆាប់ខឹង ឆាប់ភ័យ, ធ្វើឱ្យមានជំងឺ រលាកថ្លើម ថ្លើមរីក, និងធ្វើឱ្យកើតអង់ស៊ីមមិនប្រក្រតី។

❖ ក្រុមសារធាតុអសរីរាង្គ។ សារធាតុទាំងនេះ បង្កឱ្យមានជំងឺសួត និងជាពិសេសជំងឺឈឺភ្នែក។

## V.ឥទ្ធិពលនៃផ្សែងទៅលើបរិស្ថាន

ផ្សែងដែលបញ្ចេញមក មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងភពផែនដីដែរ។ ផលប៉ះពាល់ទាំងនោះរួមមានភ្លៀងអាស៊ីត ផែនដីឡើងកំដៅ និងការធ្លុះធ្លាយស្រទាប់អូហ្សូន។

❖ **បញ្ហាភ្លៀងអាស៊ីត**។ មូលហេតុដែលធ្វើឱ្យមានភ្លៀងអាស៊ីត គឺបណ្ដាលមកពីឧស្ម័នអាស៊ីតស៊ុលហ្វួរី ឧស្ម័នអាស៊ីតស៊ុលហ្វួរិក ឧស្ម័នអាស៊ីតនីត្រី ឧស្ម័នអាស៊ីតនីទ្រិក និងបណ្ដាឧស្ម័នអាស៊ីតដទៃទៀត ដែលនៅលាយឡំក្នុងខ្យល់បរិយាកាស ប៉ះជាមួយចំហាយទឹក ឬទឹកភ្លៀង ទើបវាបណ្ដាលឱ្យមានភ្លៀងអាស៊ីតធ្លាក់ចុះមក។ ភ្លៀងអាស៊ីត នឹងបង្កឱ្យមានផលប៉ះពាល់ខ្លាំងដល់ធម្មជាតិដែលនៅជុំវិញខ្លួនយើង ជាពិសេសចំពោះរុក្ខជាតិ ផលដំណាំ សត្វ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជាពិសេសសំណង់អាគារ។




*បន្ទុំនៃសកម្មភាពមនុស្ស និងធម្មជាតិ ដែលបង្កើតឱ្យមានសមាសធាតុភ្លៀងអាស៊ីត។*

❖ **បញ្ហាផែនដីឡើងកំដៅ**។ បញ្ហាផែនដីឡើងកំដៅគឺជាបញ្ហា**មួយធ្ងន់ធ្ងរជាងគេបំផុតក្នុងចំណោមបញ្ហាទាំងបីនេះ**។ មូលហេតុដែល**ធ្វើឱ្យផែនដីឡើងកំដៅ** គឺដោយសារចំហាយទឹក និងឧស្ម័នកាបូនិក ព្រមទាំងឧស្ម័នផ្សេងៗមួយចំនួនទៀត ដែលចាប់ស្រូបយកថាមពលព្រះអាទិត្យ (កំដៅ)។ ការចាប់ស្រូបយកថាមពលនេះ បានធ្វើឱ្យខ្យល់បរិយាកាសឡើងក្ដៅ។ កំណើនកំដៅបរិយាកាសកើនឡើង ឬថយចុះ គឺសមាមាត្រទៅ លើបរិមាណកំហាប់របស់ចំហាយទឹក និងឧស្ម័នកាបូនិកនៅក្នុងបរិយាកាស។ បើកាលណាកំហាប់របស់ចំហាយទឹក និងឧស្ម័នកាបូនិកកាន់តែច្រើន នោះកំដៅបរិយាកាសក៏កាន់តែឡើងក្ដៅខ្លាំងដែរ។ ម្យ៉ាងវិញទៀត បរិមាណកំហាប់របស់ចំហាយទឹក និងឧស្ម័នកាបូនិកកាន់តែច្រើន ធ្វើឱ្យការចាំងផ្លាតត្រឡប់ពី ផែនដីវិញនូវកាំរស្មីព្រះអាទិត្យ និងរលកកំដៅ ទៅកាន់លំហបរិយាកាសខាងក្រៅមិនអាចប្រព្រឹត្តទៅរួច ដែលជាមូលហេតុធ្វើឱ្យខ្យល់បរិយាកាសខាងក្នុងកាន់តែក្ដៅឡើងៗ។ ជាឧទាហរណ៍ យើងអាចប្រៀបធៀបរបៀបដែលកំដៅបរិយាកាសខាងក្នុងកើនឡើង ទៅនឹងរថយន្តមួយដែលបិទកញ្ចក់ជិតទាំងអស់ ហើយទុកវាចោលនៅក្រោមកំដៅថ្ងៃ។ ពេលនោះយើងសង្កេតឃើញថា ខ្យល់នៅក្នុងរថយន្ត មានកំដៅក្ដៅជាងខ្យល់នៅខាងក្រៅរថយន្ត។ ម្យ៉ាងវិញទៀត បើកាលណាផែនដីឡើងកំដៅ នោះវានឹងធ្វើឱ្យទឹកកកនៅប៉ូលទាំងពីររលាយ ដែលបណ្ដាលឱ្យកំពស់ទឹកសមុទ្រកើនឡើង ធ្វើឱ្យលិចលង់តំបន់ទំនាបនៅតាមមាត់សមុទ្រ។ ជាមួយគ្នានេះដែរ ការឡើងកំដៅនេះនឹងធ្វើឱ្យមានរំហួតទឹកខ្ពស់ ដែលបង្កឱ្យមានភ្លៀងធ្លាក់កាន់តែច្រើនឡើងៗ បណ្ដាលឱ្យមានគ្រោះទឹកជំនន់ ការហូរច្រោះដី ...។ល។ កំដៅ

បរិយាកាសកើនឡើង កំរួមចំណែកធ្វើឱ្យមានភ្លើងឆេះព្រៃដែរ ។ ឧទាហរណ៍ នៅឆ្នាំ២០០៣ មានភ្លើងឆេះព្រៃបានរាតត្បាតសឹងគ្រប់ទីកន្លែង ដូចជានៅទ្វីបអាមេរិក អឺរ៉ុប អូស្ត្រាលី ។

❖ **បញ្ហាធ្លុះធ្លាយស្រទាប់អូហ្សូន** ។ អូហ្សូន គឺជាស្រទាប់បរិយាកាសមួយដែលរាំងកាំរស្មីស្វាយអ៊ុលត្រា ( កាំរស្មីពណ៌ស្វាយ ) ពីព្រះអាទិត្យ មិនឱ្យមកដល់ស្រទាប់បរិយាកាសខាងក្រោមបាន ( ស្រទាប់បរិយាកាសដែលនៅជាប់នឹងផែនដី ) ។ កាំរស្មីស្វាយអ៊ុលត្រា នឹងបង្កឱ្យមានជំងឺរលាកស្បែក ជំងឺភ្នែកឡើងបាយ មហារីកស្បែក ។ល។ ឥឡូវនេះ គេសង្កេតឃើញថាស្រទាប់អូហ្សូនត្រូវបានធ្លុះធ្លាយនៅ តាមតំបន់មួយចំនួនក្បែរប៉ូលខាងត្បូង ។ ការធ្លុះធ្លាយនេះ គឺបណ្តាលមកពីសារធាតុក្លរ-ហ្លុយអរ៉ូកាបូន ដែលមានប្រតិកម្មគីមីជាមួយស្រទាប់អូហ្សូន ធ្វើឱ្យស្រទាប់នេះខូចខាត ។ សារធាតុនេះមាននៅក្នុងគ្រឿងម៉ាស៊ីនត្រជាក់ ស្ព្រាយបាញ់សក់ សារធាតុធ្វើឱ្យត្រជាក់សំរាប់ក្លាសេបន្លែ ផ្លែឈើ សាច់ ។ល។

## VI. ដំណោះស្រាយដើម្បីកាត់បន្ថយឥទ្ធិពលផ្សែង

❖ ដើម្បីជៀសឱ្យផុតពីឥទ្ធិពលនៃផ្សែងទាំងនោះ យើងអាចរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញផ្សែង ដោយត្រូវ:

❖ ជៀសវាងការដុតសារធាតុប្លាស្ទិក ជាតិជ័រ និងសារធាតុនានាដែលផ្ទុកទៅដោយជាតិពុល

❖ ចូលរួមប្រើប្រាស់ប្រេងឥន្ធនៈណា ដែលគ្មានសំណ និងម៉ង់ហ្គាណែស តាមលទ្ធភាពដែលអាចធ្វើទៅបាន

❖ ប្រើប្រាស់ឥន្ធនៈណា ដែលមានផ្សែងតិច ដូចជាឧស្ម័នផ្សងឈើ ថាមពលព្រះអាទិត្យ វារីយោអគ្គិសនី វារីអគ្គិសនី ។ល។

❖ ចូលរួមប្រើយានជំនិះសាធារណៈឱ្យបានច្រើន

❖ រោងចក្រ-សហគ្រាស ដែលបញ្ចេញផ្សែងត្រូវធ្វើការសំអាត និងច្រោះយកសារធាតុពុលទាំងនោះចេញ មុននឹងបញ្ចេញផ្សែងទាំងនោះចោល

❖ ចូលរួមចំណែកសំអាតទីក្រុងរបស់យើង ដោយរៀបចំទុកដាក់សំរាមទៅតាមប្រភេទរបស់វា ដូចជាសារធាតុស្អុយរលួយត្រូវទុកដាក់ដោយឡែកសំរាប់ធ្វើជីធម្មជាតិ សារធាតុប្លាស្ទិក ត្រូវទុកដាក់ដោយឡែកសំរាប់ប្រើប្រាស់ឡើងវិញ ឬក៏យកវាទៅផលិតឡើងវិញ ។ល។

❖ កាត់បន្ថយការប្រើប្រាស់ផលិតផល ដែលផលិតពីសារធាតុប្លាស្ទិក តាមលទ្ធភាពដែលអាចធ្វើទៅបាន

❖ នៅឱ្យឆ្ងាយពីទីលានដុតសំរាម ពីប្រភពបញ្ចេញផ្សែង ។

❖ ប្រើប្រាស់ឡើងវិញនូវសំភារៈដែលប្រើរួចហើយ បន្ថយការប្រើប្រាស់សំភារៈមិនចាំបាច់នានា និងធ្វើការកែច្នៃផលិតឡើងវិញនូវរបស់របរដែលប្រើរួចហើយ ។

រៀបរៀងដោយ **រាត់ ស៊ិទ្ធ**

ប្រធានការិយាល័យអប់រំ

**កំប្លែងបរិស្ថាន**

## មនុស្សគ្រាកដជាស៊ីស្មៅ?

**ទ្រឹស្ដីវិទ្យាសា**[illegible]**ៈសកល** មានចរិតសុក្រឹត្យ ត្រឹមត្រូវគ្រប់[illegible] ។

[illegible] **ដែលឆ្លងពីយុគសម័យមួយមក** [illegible] **ហើយសព្វថ្ងៃនេះ**មនុស្សលោកកំពុងស្ថិត [illegible]**ការរីកចំរើន**វិទ្យាសាស្ត្របច្ចេកទេសនេះ [illegible]

[illegible]**ក៏មានចរិត**សកលដែរ តែវាមានភាពទន់ភ្លន់យឺតឬរួញ [illegible]**ទ្រឹស្ដីវិទ្យា**សាស្ត្រ ។ ដូចជាទ្រឹស្ដីនៃការតស៊ូវណ្ណៈបានថែងថា "[illegible]*ជាន់ទីនោះមានការតស៊ូ ឬ" យុត្តិធម៌តែងឈ្នះអយុត្តិធម៌* ។ **ទ្រឹស្ដីសង្គមបើគ្មានសកម្មភាព** មគ្គុទ្ទេសក៍នយោបាយជាអ្នកដឹកនាំអនុវត្តន៍ និង មានមនុស្សចូលរួមអនុវត្តន៍ទេនោះ "**គឺសង្គមគ្មានការប្រែប្រួលឬផ្លាស់ប្ដូរអ្វីឡើយ**" ។

ទាំងទ្រឹស្ដីវិទ្យាសាស្ត្រនិងទ្រឹស្ដីសង្គម សុទ្ធតែជាសមិទ្ធផលដែលអ្នកប្រាជ្ញបានរកឃើញ ហើយចងក្រងទុកជាមេរៀនសំរាប់ មនុស្សយកទៅដឹកនាំ និងកសាងសង្គមអោយឆ្ពោះទៅរកការរីកចំរើន...... ។

---

ថ្ងៃមួយ ក្នុងថ្នាក់រៀនមួយពេលចាប់ផ្ដើមសិក្សាមេរៀន ជីវៈវិទ្យា លោកសាស្ត្រាចារ្យបានធ្វើការបកស្រាយទ្រឹស្ដីគណិតវិទ្យា មួយដែលទាក់ទងនឹងមេរៀន ជីវៈវិទ្យា.........

***លោកសាស្ត្រាចារ្យ*** *: យោងតាមទ្រឹស្ដីគណិតវិទ្យា:*

*បើ ក ស្មើនឹង ខ*

*ហើយ ខ ស្មើនឹង គ*

*នាំអោយ ក ស្មើនឹង គ ។*

ដូច្នេះយោងតាមអំណៈអំណាងខាងលើ ខ្ញុំ( លោកសាស្ត្រាចារ្យ) សូមលើកបញ្ហាមួយដូចខាងក្រោមអោយប្អូនៗ ដោះស្រាយ ។ បញ្ហានោះគឺ:

*-គោស៊ីស្មៅ*

*-មនុស្សស៊ីសាច់គោ*

*-តើប្អូនអាចសន្និដ្ឋានថាមនុស្សស៊ីស្មៅដែរ ឬទេ?*

**នាយដួច:** ប្រាកដណាស់លោកសាស្ត្រាចារ្យមនុស្សក៏ស៊ីស្មៅដែរព្រោះទ្រឹស្ដីគណិតវិទ្យាបានថែងយ៉ាងដូច្នេះ ។

**លោកសាស្ត្រាចារ្យ**..................!!!!!! ។

ដូច្នេះសូមមិត្តអ្នកអានទស្សនាវដ្ដី មេត្តាជួយដោះស្រាយបញ្ហានេះផង តើនាយដួចបកស្រាយត្រឹមត្រូវឬទេ? ។ ដោយៈ **នាយឃ្មេ**

**កំណាព្យបរិស្ថាន**

## ប្រយោជន៍ព្រៃកោងកាង

( កំណាព្យ បទពាក្យ៧ )

១. ព្រៃតំបន់ឆ្នេរក្បែរសមុទ្រ ប្រយោជន៍បំផុតគឺកោងកាង
ជារបាំងខ្យល់បក់ពីម្ខាង ការពារភូមិស្ថានបានគង់វង្ស ។

២. កោងកាងជំរកព្រៃធម្មជាតិ ជីវៈច្រើនទៀតកកើតមាន
ជាទីកន្លែងដ៏សុខសាន្ត សត្វពងកូនបានមានចំណី ។

៣. កោងកាងធ្វើជាសំពោងបាន សសរផ្ទោងផ្ទានយ៉ាងប្រពៃ
ឬធ្វើអុសធ្យូងល្អពេកក្រៃ ឬតាមចិត្តឆ្នៃតុទូតាំង ។

៤. កោងកាងការពារឆ្នេរសមុទ្រ ឱ្យចៀសវាងផុតការបាក់ច្រាំង
ពេលរលកបោកបក់ខ្លាំងៗ វាជារបាំងយ៉ាងសុវត្ថិ ។

៥. ដូច្នេះចូរយើងទាំងអស់គ្នា សាមគ្គីសាមគ្គាទាំងកាយចិត្ត
ការពារកោងកាងយ៉ាងមធ្យ័ត បើមិនប្រយ័ត្នបាត់និរន្តរ៍ ។

៦. ប្រឆាំងអំពើរុករានដី កាប់ទន្ទ្រានព្រៃមិនគិតគន់
អាងតែអំពោចចិត្តលោភលន់ នាំគ្រោះអាសន្នដល់សង្គម ។

៧. បង្កើនស្មារតីថែរក្សា ឱ្យបានគ្រប់គ្នាគ្រប់កន្លែង
កោងកាងដែលមានឱ្យធាប់ធំ និងត្រូវខិតខំដាំថែមទៀត ។

៨. ខិតខំដាំដុះគ្រប់ទិសទី ប្រុសស្រីមូលមីរខំប្រឹងឆ្លៀត
ដាំថែមតាមឆ្នេរដុះព្រោងព្រាត ជំនួសព្រៃបាត់បង់ពីមុន ។

៩. កោងកាងជាទ្រព្យដ៏ថ្លៃថ្លា កោងកាងរក្សាមានគុណធ្ងន់
សួយជីវិតយើងក្នុងតំបន់ ឱ្យផុតអាសន្នគ្រោះក្រៃក្រ ។

និពន្ធដោយលោក **ខឹម_ម៉ុនះហេង**

ប្រធានមន្ទីរបរិស្ថានខេត្តកំពត

អភិវឌ្ឍន៍ដោយនិរន្តរភាព
បរិស្ថានរួមមានវិសាល
ភាពបីគឺៈ សេដ្ឋកិច្ច
អេកូឡូស៊ី និង សង្គម

SUSTAINABLE DEVELOPMENT COMPRISES THREE DIMENSIONS: ECONOMIC , ECOLOGY AND SOCIAL





ភពផែនដី និង ព្រៃឈើ
សំរាប់មនុស្សជំនាន់មុន
ជំនាន់បច្ចុប្បន្ន និង
មនុស្សជំនាន់ក្រោយ

THE EARTH AND FOREST ARE FOR PAST , PRESENT AND FUTURE GENERATION

រស់នៅលើភពផែនដីបាន
អាស្រ័យដោយបរិស្ថាន
ស្អាត និង បរិស្ថាន
ប្រកបដោយផាសុកភាព

LIFE ON EARTH DEPENDS ON CLEAN AND HEALTHY ENVIRONMENT



